ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២៤ លេខ៣៥ ត្រីមាសទី០២ ឆ្នាំ២០២៤

# រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ៤-៣-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៤/២៣៧ ស្តីពី ការបញ្ចប់មុខតំណែងពីទីប្រឹក្សា និងជំនួយការ ឯកឧត្តម **ខង្សី ទិស្សុត** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈ-រដ្ឋមន្ត្រី ចំនួន ៣រូប | ៤៧៧១ |
| ៤-៣-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៤/២៣៨ ស្តីពី ការតែងតាំងមុខតំណែងឯកឧត្តម **ឡាយ ណូវ៉ា** ជាអនុរដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ៤៧៧២ |
| ៤-៣-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៤/២៣៩ ស្តីពី ការបញ្ចប់មុខតំណែងពីទីប្រឹក្សា និងជាជំនួយការទីស្តីការគណៈរដ្ឋមន្ត្រី ២៣រូប | ៤៧៧៣ |
| ៤-៣-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៤/២៤០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ដល់សប្បុរសជនសញ្ជាតិកាណាដា ១៤ រូប | ៤៧៧៥ |
| ៥-៣-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៤/២៤១ ស្តីពី ការតែងតាំង ឯកឧត្តម ២រូប ជាសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ជ្រើសតាំងដោយរដ្ឋសភា នីតិកាលទី៧ | ៤៧៧៦ |
| ៦-៣-២០២៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៤/២៤២ ស្តីពី ការតែងតាំងជាសមាជិកព្រឹទ្ធសភា នៃព្រះរាជា-ណាចក្រកម្ពុជា ២ព្រះអង្គ ចាត់តាំងដោយ ព្រះមហាក្សត្រ សម្រាប់នីតិកាលទី៥ | ៤៧៧៧ |


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


| | | |
|---|---|---|
| ១-៣-២០២៤ | -អនុក្រឹត្យលេខ ៤៤ អនក្រ.បក ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសន្តិសុខឌីជីថល | ៤៧៧៨ |
| ១១-៣-២០២៤ | -អនុក្រឹត្យលេខ ៤៥ អនក្រ.បក ស្តីពី គុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ | ៤៧៨៥ |
| ១១-៣-២០២៤ | -អនុក្រឹត្យលេខ ៤៦ អនក្រ.បក ស្តីពី ការកែសម្រួលអត្រាពន្ធគយ និងអត្រាអាករពិសេសលើផលិតផលតេលសិលាមួយចំនួន | ៤៧៩៨ |
| ១១-៣-២០២៤ | -អនុក្រឹត្យលេខ ៤៧ អនក្រ.បក ស្តីពី ពន្ធប៉ាតង់ | ៤៨០០ |
| ១១-៣-២០២៤ | -អនុក្រឹត្យលេខ ៤៨ អនក្រ.បក ស្តីពី កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងកម្រិតប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ | ៤៨០២ |
| ២៣-២-២០២៤ | -អនុក្រឹត្យលេខ ១៣៤ អនក្រ.តត ស្តីពី ការបញ្ចប់មុខតំណែងមន្ត្រីរាជការ | ៤៨០៥ |
| ២៦-២-២០២៤ | -អនុក្រឹត្យលេខ ១៣៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ | ៤៨០៦ |
| ១-៣-២០២៤ | -អនុក្រឹត្យលេខ ១៣៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៤៨០៨ |
| ១-៣-២០២៤ | -អនុក្រឹត្យលេខ ១៣៩ អនក្រ.តត ស្តីពី ការផ្ទេរ និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា | ៤៨០៩ |
| ១-៣-២០២៤ | -អនុក្រឹត្យលេខ ១៤០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ | ៤៨១០ |

១-៣-២០២៤ -អនុក្រឹត្យលេខ ១៤១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៨១២

១-៣-២០២៤ -អនុក្រឹត្យលេខ ១៤២ អនក្រ.តត ស្តីពី ការបញ្ចប់មុខតំណែងជំនួយការទីស្តីការគណៈ-រដ្ឋមន្ត្រី ៤៨១៤

៧-៣-២០២៤ -អនុក្រឹត្យលេខ ១៤៣ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិជាកិច្ច-បច្ឆាមរណៈ ៤៨១៦

៧-៣-២០២៤ -អនុក្រឹត្យលេខ ១៤៤ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិជាកិច្ច-បច្ឆាមរណៈ ៤៨១៧

៧-៣-២០២៤ -អនុក្រឹត្យលេខ ១៤៧ អនក្រ.តត ស្តីពី ការបញ្ចប់មុខតំណែងនិងតែងតាំងមន្ត្រីរាជការ ៤៨១៨

៧-៣-២០២៤ -អនុក្រឹត្យលេខ ១៤៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៨២០

៧-៣-២០២៤ -អនុក្រឹត្យលេខ ១៤៩ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៤៨២៨

៧-៣-២០២៤ -អនុក្រឹត្យលេខ ១៥០ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៨៣២

៧-៣-២០២៤ -អនុក្រឹត្យលេខ ១៥១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤៨៣៣

៧-៣-២០២៤ -អនុក្រឹត្យលេខ ១៥២ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៤៨៣៧

៧-៣-២០២៤ -អនុក្រឹត្យលេខ ១៥៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៨៤១

១២-៣-២០២៤ -អនុក្រឹត្យលេខ ១៥៥ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិ ៤៨៤៥

១២-៣-២០២៤ -អនុក្រឹត្យលេខ ១៥៦ អនក្រ.តត ស្តីពី ការផ្តល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការ និងសប្បុរសជន ៤៨៤៧

១៣-៣-២០២៤ -អនុក្រឹត្យលេខ ១៥៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៤៨៤៩


## ២~សេចក្តីសម្រេច


២២-២-២០២៤ -សេចក្តីសម្រេចលេខ ៤៤ សសរ ស្តីពី ការតែងតាំងសមាសភាពគណៈកម្មការចំពោះកិច្ចចុះបញ្ជីដីតំបន់ទន្លេសាប ៤៨៥០

១១-៣-២០២៤ -សេចក្តីសម្រេចលេខ ៥២ សសរ ស្តីពី ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំកិច្ចប្រជុំប្រចាំឆ្នាំថ្នាក់រដ្ឋមន្ត្រីការពារជាតិនិងធ្វើលំហាត់សមយុទ្ធរួមរវាងកងទ័ពបីប្រទេស កម្ពុជា ឡាវ វៀតណាម នៅព្រះរាជាណាចក្រកម្ពុជា ៤៨៥៣


## ៣~សេចក្តីណែនាំ


១-៣-២០២៤ -សេចក្តីណែនាំលេខ ០២ សរណន ស្តីពី ការពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពក្នុងការបំពេញការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ៤៨៥៧


# III~ការងារបណ្តាក្រសួង

## ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


២៤-១-២០២៤ -ប្រកាសលេខ ០៦៦ សហវ.ប្រក.អរថ ស្តីពី ការបង្កើត និងការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពត្រួតពិនិត្យថវិកានៅអមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ៤៨៥៩

| | | |
|---|---|---|
| ៨-២-២០២៤ | -ប្រកាសលេខ ១១៩ សហវ.ប្រក.អពជ ស្តីពី ការលើកទឹកចិត្តពន្ធដារចំពោះសហគ្រាសក្នុងវិស័យទេសចរណ៍ | ៤៨៦៤ |
| ៨-២-២០២៤ | -ប្រកាសលេខ ១២០ សហវ.ប្រក.អពជ ស្តីពី ការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលរបស់សហគ្រាសឧស្សាហកម្មផ្នែកវាយនភ័ណ្ឌកាត់ដេរ | ៤៨៦៧ |
| ៥-២-២០២៤ | -ប្រកាសលេខ ០០៥ សហវ.ស.ណ.ន. បគហ ស្តីពី ការអនុវត្តនីតិវិធីសម្រាប់ការចំណាយថវិកាចរន្ត ក្នុងក្របខ័ណ្ឌរដ្ឋបាលខណ្ឌតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) | ៤៨៧០ |


## ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍


| | | |
|---|---|---|
| ២-១០-២០២៣ | -ប្រកាសលេខ ៣៩០ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វីប៊ីកា ហ៊ៃ ប្រដាក់ (ខេមបូឌា) បង្កើតរោងចក្រ ផលិតសក់សប្បនិម្មិត | ៤៨៧៩ |
| ៦-១០-២០២៣ | -ប្រកាសលេខ ៣៩២ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វីចប៉ែក (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតកាបូបគ្រប់ប្រភេទ | ៤៨៨២ |
| ៦-១០-២០២៣ | -ប្រកាសលេខ ៣៩៣ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ធីដាប់ប៉ែលយូ ឡែថ៍ ឯ.ក បង្កើតរោងចក្រ ផលិតអំពូលភ្លើងគ្រប់ប្រភេទ | ៤៨៨៥ |
| ៦-១០-២០២៣ | -ប្រកាសលេខ ៣៩៤ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យូ ចាស្ត ហ្វ៊ុតវែរ (ខេមបូឌា) ឯ.ក បង្កើតរោងចក្រផលិតស្បែកជើង | ៤៨៨៨ |
| ៦-១០-២០២៣ | -ប្រកាសលេខ ៣៩៥ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វេន ដេស ភ្នំពេញ ខ្លូស៊ីង ឯ.ក បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ | ៤៨៩១ |
| ៦-១០-២០២៣ | -ប្រកាសលេខ ៣៩៦ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ិនធីហ្គ្រីធី យូញៀន ភែកឃីជីង មេធៀរៀល ឯ.ក បង្កើតរោងចក្រផលិតសម្ភារវេចខ្ចប់គ្រប់ប្រភេទពីប្លាស្ទិក | ៤៨៩៤ |
| ៦-១០-២០២៣ | -ប្រកាសលេខ ៣៩៧ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជីន លូ យ៉ន អេនើជី អ៊ិនវ៉ាយរ៉ិនម៉ិនថល ប្រ៉ូថេកសិន អ៊ិនដាស់ស្រ្ទី ឯ.ក បង្កើតរោងចក្របោកគក់ | ៤៨៩៧ |
| ៦-១០-២០២៣ | -ប្រកាសលេខ ៣៩៨ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យ៉ុងចិន អ៊ិនធើណេ-សិនណល ហៅហូល (ខេមបូឌា) ឯ.ក បង្កើតរោងចក្រផលិតសម្ភារប្រើប្រាស់ក្នុងផ្ទះ អំពូលភ្លើងគ្រប់ប្រភេទ គ្រឿងបង្គុំរាំងនន និងប្រដាប់ដាក់ចំណីសត្វ | ៤៩០០ |

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៤/៥៣៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៣៧ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍សម្រាប់ការតែងតាំងទីប្រឹក្សា និងជំនួយការនៅក្នុងអង្គការនីតិប្រតិបត្តិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : បញ្ចប់មុខតំណែងពីទីប្រឹក្សា និងជំនួយការ **ឯកឧត្តម វង្សី វិស្សុត** ឧបនាយករដ្ឋមន្ត្រី ប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ៣ រូប ៖

១-ឯកឧត្តម **ចន្ថា ម៉េងលី** ទីប្រឹក្សា មានឋានៈស្មើ អនុរដ្ឋលេខាធិការ
២-លោកជំទាវ **ឈុន វីរៈវឌ្ឍនា** ទីប្រឹក្សា មានឋានៈស្មើ អនុរដ្ឋលេខាធិការ
៣-ឯកឧត្តម **អ៊ឹង ឥន្ទហ៊ាង** ជំនួយការ មានឋានៈស្មើ អគ្គនាយក។

**មាត្រា២** : សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០២៤
**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ការល. ៥៤០៣.៥៣៧

ហ.ស.

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានយកទូលថ្វាយសូមឡាយព្រះហស្តលេខា
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៤/២៣៨

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងមុខតំណែងឯកឧត្តម **ឡាយ ណូរ៉ា** ជាអនុរដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០២៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

ពរល.២៤០៣.២៣៨

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៤/៤៣៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៣៧ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍សម្រាប់ការតែងតាំងទីប្រឹក្សា និងជំនួយការនៅក្នុងអង្គការនីតិប្រតិបត្តិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : បញ្ចប់មុខតំណែងពីទីប្រឹក្សា និងជំនួយការទីស្តីការគណៈរដ្ឋមន្ត្រី ២៣រូប៖

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **ប្រាក់ ធុច** | ទីប្រឹក្សា | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ២- | ឯកឧត្តម | **ចៅ សុផុន** | ទីប្រឹក្សា | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៣- | ឯកឧត្តម | **ឥន្ទ សុខាវុធ** | ទីប្រឹក្សា | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៤- | ឯកឧត្តម | **ឡូ សុភៈរស្មី** | ទីប្រឹក្សា | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៥- | ឯកឧត្តម | **ប៊ិន សូឈី** | ទីប្រឹក្សា | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៦- | ឯកឧត្តម | **ឌួង លាង** | ទីប្រឹក្សា | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៧- | ឯកឧត្តម | **ហេង វ៉ាន់ដា** | ទីប្រឹក្សា | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៨- | ឯកឧត្តម | **តែ ឡូរិន** | ទីប្រឹក្សា | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៩- | ឯកឧត្តម | **កែវ សុខឃាង** | ទីប្រឹក្សា | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ១០- | ឯកឧត្តម | **ម៉ៅ សុភាព** | ទីប្រឹក្សា | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

១១- ឯកឧត្តម **ឃឹម សំអាង** ទីប្រឹក្សា មានឋានៈស្មើ អនុរដ្ឋលេខាធិការ
១២- ឯកឧត្តម **ង៉ែត ឆៃលី** ទីប្រឹក្សា មានឋានៈស្មើ អនុរដ្ឋលេខាធិការ
១៣- លោកជំទាវ **ហង់ មូលីសានីន** ទីប្រឹក្សា មានឋានៈស្មើ អគ្គនាយក
១៤- ឯកឧត្តម **ឌី សេរីវីរៈ** ទីប្រឹក្សា មានឋានៈស្មើ អគ្គនាយក
១៥- ឯកឧត្តម **ឈឿង នរិន្ទមុនី** ទីប្រឹក្សា មានឋានៈស្មើ អគ្គនាយក
១៦- ឯកឧត្តម **ឃឹម រ៉ូឡឺ** ទីប្រឹក្សា មានឋានៈស្មើ អគ្គនាយក
១៧- ឯកឧត្តម **សន សេត** ទីប្រឹក្សា មានឋានៈស្មើ អគ្គនាយក
១៨- ឯកឧត្តម **ហ៊ុន សុខា** ជំនួយការ មានឋានៈស្មើ អគ្គនាយក
១៩- ឯកឧត្តម **ស្រេង ម៉ាប់** ជំនួយការ មានឋានៈស្មើ អគ្គនាយក
២០- ឯកឧត្តម **គឹម សទ្វាត** ជំនួយការ មានឋានៈស្មើ អគ្គនាយក
២១- ឯកឧត្តម **ធាង សាក់** ជំនួយការ មានឋានៈស្មើ អគ្គនាយក
២២- ឯកឧត្តម **ឃុត កែវសុស្លា** ជំនួយការ មានឋានៈស្មើ អគ្គនាយក
២៣- ឯកឧត្តម **ឃិន សុភី** ជំនួយការ មានឋានៈស្មើ អគ្គនាយក។

**មាត្រា២** : តែងតាំងជាទីប្រឹក្សាទីស្ដីការគណៈរដ្ឋមន្ត្រី ៦រូបៈ

១- ឯកឧត្តម **ង៉ែត ឆៃលី** ដោយពុំទទួលប្រាក់បំណាច់មុខងារ
២- ឯកឧត្តម **ឌួង ណាង** ដោយពុំទទួលប្រាក់បំណាច់មុខងារ
៣- ឯកឧត្តម **ហេង វ៉ាន់ដា** ដោយពុំទទួលប្រាក់បំណាច់មុខងារ
៤- ឯកឧត្តម **តែ ឡារិន** ដោយពុំទទួលប្រាក់បំណាច់មុខងារ
៥- ឯកឧត្តម **ឃឹម រ៉ូឡឺ** ដោយពុំទទួលប្រាក់បំណាច់មុខងារ
៦- ឯកឧត្តម **សន សេត** ដោយពុំទទួលប្រាក់បំណាច់មុខងារ។

**មាត្រា៣** : សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០២៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

[illegible]

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៤/៤៤០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**ដល់សប្បុរសជនសញ្ជាតិកាណាដា ១៤រូបៈ

| | | | |
|---|---|---|---|
| ១-លោក | SIFTON DAVID RICHARD | ២-លោកស្រី | SIFTON KIMBERLEY SUZANNE |
| ៣-លោក | BINDER DUNCAN MURRAY | ៤-លោកស្រី | BINDER CATHERINE GWYN |
| ៥-លោកស្រី | TE HOUY ENG | ៦-លោក | KORN LYLA |
| ៧-លោកស្រី | HAUCK LILLY JOANNE | ៨-លោក | LAYLAND KOLTON MYKENZIE |
| ៩-លោកស្រី | LAYLAND TENA LINDA | ១០-លោកស្រី | WONITOY MELANIE LEE |
| ១១-លោក | ZELENAK PATRICK JOHN | ១២-លោក | LETENDRE ROBERT JAMES LEE |
| ១៣-លោកស្រី | LETENDRE ROXANENE LORRAINE | ១៤-លោកស្រី | ZELENAK CYNTHIA LEE |

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០២៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ពរស.៤៤០៣.៤៤០

ស.ជ.ស.

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានអមស្នាក្រឹត្យត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

វង្សី វិស្សុត

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៤/៥៤១

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៦ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ចំនួន ២រូប ដោយរដ្ឋសភា នីតិកាលទី៧ នៅក្នុងសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៧ នាថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំង ៖

១-ឯកឧត្តម **សុខ ឥសាន** ជាសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ជ្រើសតាំងដោយរដ្ឋសភា នីតិកាលទី៧

២-ឯកឧត្តម **ហោង ហាលីម** ជាសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ជ្រើសតាំងដោយរដ្ឋសភា នីតិកាលទី៧

**មាត្រា២** : ព្រឹទ្ធសភា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០២៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

៣៤៧.៥៤០៣.៥៤១

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៤/[illegible]

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៦ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានទ្រង់យល់សំណូមពរចាំបាច់ចំពោះមុខ

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងជាសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ០២ព្រះអង្គ ចាត់តាំងដោយ **ព្រះមហាក្សត្រ** សម្រាប់នីតិកាលទី៥ :

១- សម្តេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី**
២- ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ធម្មិកោ**

**មាត្រា២** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

[illegible]

**បានប្រទាប់ព្រះរាជលញ្ឆករហើយ**

*ធ្វើនៅថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០២៤*

**នរោត្តម សីហមុនី**

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
លេខ: [illegible] រ.ចប
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ [illegible]
ទេសរដ្ឋមន្ត្រីទទួលបន្ទុកភារកិច្ចទូទៅ អមក្រសួងព្រះបរមរាជវាំង

**ឧកញ៉ា មហាមន្ត្រី គួយ សុផល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសន្តិសុខឌីជីថល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២១/៥៦៤ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២១ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសន្តិសុខឌីជីថល ដែល សរសេរជាអក្សរកាត់ថា **គ.ស.ឌ.** ក្នុងគោលបំណងធានាប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃការបំពេញមុខងារ ដឹកនាំ សម្របសម្រួល និងជំរុញការគ្រប់គ្រងសន្តិសុខឌីជីថល ដើម្បីការពារអត្ថប្រយោជន៍របស់គ្រប់តួអង្គ សង្គមទប់ទល់នឹងការវាយប្រហារគ្រប់រូបភាព ឆ្លើយតបគ្រប់ផ្នែកទាំងបច្ចេកទេសនិងកម្លាំងពាក់ព័ន្ធនឹង ការធានានិងការពារសន្តិសុខឌីជីថល។

## ជំពូកទី២

## តួនាទីនិងភារកិច្ចរបស់ គ.ស.ឌ.

**មាត្រា២ .-**

**គ.ស.ឌ.** មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ដឹកនាំ សម្របសម្រួល និងជំរុញការគ្រប់គ្រងសន្តិសុខឌីជីថល ដែលរួមមាន សន្តិសុខសាយប័រ ឧក្រិដ្ឋកម្មសាយប័រ ការការពារជាតិក្នុងលំហសាយប័រ និងការទូតសាយប័រ
- ដឹកនាំសម្របសម្រួលកម្រិតនយោបាយ និងដាក់វិធានការក្នុងការឆ្លើយតបឧប្បត្តិហេតុសន្តិសុខសាយប័រសំខាន់ៗ និងការទប់ស្កាត់ហានិភ័យសន្តិសុខសាយប័រ ទាំងវិស័យសាធារណៈនិងវិស័យឯកជន
- ពិនិត្យនិងសម្រេចលើសំណើរៀបចំ កែសម្រួល និង/ឬធ្វើវិសោធនកម្មច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធនឹងសន្តិសុខឌីជីថល
- ជំរុញនិងពិនិត្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសន្តិសុខឌីជីថល
- គ្រប់គ្រងនិងប្រមូលផ្តុំទិន្នន័យពាក់ព័ន្ធនឹងសន្តិសុខឌីជីថល
- សម្របសម្រួលនិងជំរុញកិច្ចសហប្រតិបត្តិការក្នុងប្រទេសនិងអន្តរជាតិពាក់ព័ន្ធនឹងសន្តិសុខឌីជីថល
- កៀរគរធនធានហិរញ្ញវត្ថុ ធនធានបច្ចេកទេស និងធនធានមនុស្ស ក្នុងបុព្វហេតុកសាងនិងអភិវឌ្ឍសន្តិសុខឌីជីថល
- ជំរុញ លើកទឹកចិត្ត និងគាំទ្រការកសាងនិងការអភិវឌ្ឍសន្តិសុខឌីជីថលពីគ្រប់មជ្ឈដ្ឋាន
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការចាំបាច់។

## ជំពូកទី៣
## សមាសភាពរបស់ គ.ស.ឌ.

**មាត្រា៣ .-**

**គ.ស.ឌ.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | ប្រធាន |
| - ឧបនាយករដ្ឋមន្ត្រី ១ រូប | អនុប្រធានប្រចាំការ |
| - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១ រូប | សមាជិក |
| - អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ | សមាជិក |
| - អគ្គស្នងការនគរបាលជាតិ | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ **គ.ស.ឌ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**គ.ស.ឌ.** អាចមានសមាសភាពបន្ថែមជាអនុប្រធានឬសមាជិកដែលជាតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត តាមការចាំបាច់។ សមាសភាពបន្ថែមនេះត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ស.ឧ.

**មាត្រា៤ .-**

**គ.ស.ឧ.** ត្រូវប្រជុំរៀងរាល់ ៦ (ប្រាំមួយ) ខែម្តង តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ ប្រធានឬអនុប្រធានប្រចាំការ **គ.ស.ឧ.** អាចកោះប្រជុំវិសាមញ្ញបាន។ ក្នុងករណីដែលប្រធាន **គ.ស.ឧ.** អវត្តមាន ឬមានករណីចាំបាច់ ប្រធាន **គ.ស.ឧ.** អាចផ្ទេរសិទ្ធិជូនអនុប្រធានប្រចាំការ ឬអនុប្រធានណាមួយ ដើម្បីដឹកនាំកិច្ចប្រជុំ។

សមាជិក **គ.ស.ឧ.** ដែលមិនអាចចូលរួមកិច្ចប្រជុំបាន ត្រូវចាត់តាំងថ្នាក់ដឹកនាំដែលមានសិទ្ធិសម្រេច ក្នុងនាមក្រសួង ស្ថាប័នខ្លួន ដើម្បីចូលរួមកិច្ចប្រជុំនិងសម្រេចជំនួស។

**មាត្រា៥ .-**

ប្រធាន **គ.ស.ឧ.** ឬអនុប្រធានប្រចាំការ ឬអនុប្រធានដែលទទួលសិទ្ធិដឹកនាំកិច្ចប្រជុំ មានសិទ្ធិអញ្ជើញ ថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ឬឥស្សរជនដែលមានបទពិសោធ សមត្ថភាព និង ជំនាញវិជ្ជាជីវៈ ចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ **គ.ស.ឧ.** តាមការចាំបាច់។

ក្នុងករណីដែលប្រធាន **គ.ស.ឧ.** មិនអាចបំពេញមុខនាទីដោយផ្ទាល់បាន ប្រធាន **គ.ស.ឧ.** អាច ចាត់តាំងអនុប្រធានប្រចាំការដឹកនាំការងារជំនួស។

**មាត្រា៦ .-**

**គ.ស.ឧ.** មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានរចនាសម្ព័ន្ធដូចខាងក្រោម៖

- អង្គភាពសន្តិសុខសាយបរកម្ពុជា
- អង្គភាពប្រឆាំងឧក្រិដ្ឋកម្មសាយបរ
- អង្គភាពការពារជាតិក្នុងលំហសាយបរ
- អង្គភាពការទូតសាយបរ
- លេខាធិការដ្ឋាន។

អង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ឧ.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៧ .-**

អគ្គលេខាធិការដ្ឋាន **គ.ស.ឧ.** ដឹកនាំដោយអគ្គលេខាធិការដែលជារដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ដែលសរសេរជាអក្សរកាត់ថា **ក.ប.ទ.** និងមានអគ្គលេខាធិការរងមួយចំនួនជាជំនួយការ ដូចខាងក្រោម៖

- អគ្គលេខាធិការរង ១ រូប ទទួលបន្ទុកអង្គភាពសន្តិសុខសាយបរកម្ពុជា ដែលជាតំណាង **ក.ប.ទ.**
- អគ្គលេខាធិការរង ១ រូប ទទួលបន្ទុកអង្គភាពប្រឆាំងឧក្រិដ្ឋកម្មសាយបរ ដែលជាតំណាងក្រសួង មហាផ្ទៃ
- អគ្គលេខាធិការរង ១ រូប ទទួលបន្ទុកអង្គភាពការពារជាតិក្នុងលំហសាយបរ ដែលជាតំណាងក្រសួង ការពារជាតិ

- អគ្គលេខាធិការរង ១ រូប ទទួលបន្ទុកអង្គភាពការទូតសាយប័រ ដែលជាតំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- អគ្គលេខាធិការរង ១ រូប ទទួលបន្ទុកលេខាធិការដ្ឋាន ដែលជាតំណាង **អ.ប.ឌ.**
- អគ្គលេខាធិការរងមួយចំនួនទៀត តាមការចាំបាច់ ដែលជាតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ។

អគ្គលេខាធិការ និងអគ្គលេខាធិការរងត្រូវបានតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលតាមសំណើរបស់រដ្ឋមន្ត្រី **អ.ប.ឌ.**។

**មាត្រា៨ .-**

អគ្គលេខាធិការដ្ឋាន **គ.ស.ឌ.** មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ដឹកនាំគ្រប់គ្រងការងារបច្ចេកទេសសន្តិសុខឌីជីថល និងជាសេនាធិការផ្ទាល់របស់ប្រធាន **គ.ស.ឌ.**
- សម្របសម្រួលការងារសន្តិសុខឌីជីថល រួមមាន អង្គភាពសន្តិសុខសាយប័រកម្ពុជា អង្គភាពប្រឆាំងឧក្រិដ្ឋកម្មសាយប័រ អង្គភាពការពារជាតិក្នុងលំហសាយប័រ និងអង្គភាពការទូតសាយប័រ ជូន **គ.ស.ឌ.**
- គ្រប់គ្រងនិងគាំទ្រការងាររដ្ឋបាលទូទៅនៃ **គ.ស.ឌ.**
- គ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សនៃ **គ.ស.ឌ.**
- រៀបចំ គ្រប់គ្រង និងប្រើប្រាស់ថវិការបស់ **គ.ស.ឌ.**
- គ្រប់គ្រងនិងរក្សាទុកឯកសារនិងទិន្នន័យទាំងឡាយពាក់ព័ន្ធនឹងសន្តិសុខឌីជីថល
- រៀបចំនិងបូកសរុបរបាយការណ៍ ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ជូន **គ.ស.ឌ.**
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធាន **គ.ស.ឌ.**។

**មាត្រា៩ .-**

អង្គភាពសន្តិសុខសាយប័រកម្ពុជាស្ថិតក្រោមសមត្ថកិច្ចរបស់ **អ.ប.ឌ.** ត្រូវបំពេញមុខងារជាសេនាធិការរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ឌ.** លើកិច្ចការសន្តិសុខសាយប័រ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពសន្តិសុខសាយប័រកម្ពុជាត្រូវកំណត់ដោយអនុក្រឹត្យដោយឡែកតាមសំណើរបស់រដ្ឋមន្ត្រី **អ.ប.ឌ.**។

**មាត្រា១០ .-**

អង្គភាពដែលទទួលបន្ទុកលើកិច្ចការស្រាវជ្រាវ ស៊ើបអង្កេត បង្ក្រាបលើបទល្មើសបច្ចេកវិទ្យា ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ត្រូវបំពេញមុខងារបន្ថែមជាអង្គភាពប្រឆាំងឧក្រិដ្ឋកម្មសាយប័រ ដែលជាសេនាធិការរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ឌ.**។ អង្គភាពប្រឆាំងឧក្រិដ្ឋកម្មសាយប័រត្រូវបំពេញតួនាទីនិងភារកិច្ចដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសន្តិសុខឌីជីថល។

**មាត្រា១១ .-**

អង្គភាពដែលទទួលបន្ទុកលើកិច្ចការការពារជាតិក្នុងលំហសាយប័រ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងការពារជាតិ ត្រូវបំពេញមុខងារបន្ថែមជាអង្គភាពការពារជាតិក្នុងលំហសាយប័រ ដែលជាសេនាធិការ

របស់អគ្គលេខាធិការដ្ឋាន **គ.ស.ឌ.**។ អង្គភាពការពារជាតិក្នុងលំហសាយប័រត្រូវបំពេញតួនាទីនិងភារកិច្ចដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសន្តិសុខឌីជីថល។

**មាត្រា១២ .-**

អង្គភាពដែលទទួលបន្ទុកលើកិច្ចការការទូតសាយប័រ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវបំពេញមុខងារបន្ថែមជាអង្គភាពការទូតសាយប័រ ដែលជាសេនាធិការរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ឌ.**។ អង្គភាពការទូតសាយប័រត្រូវបំពេញតួនាទីនិងភារកិច្ចដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសន្តិសុខឌីជីថល។

**មាត្រា១៣ .-**

លេខាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋាន **គ.ស.ឌ.** មានថ្នាក់ស្មើនាយកដ្ឋាន ត្រូវដឹកនាំដោយប្រធាន ១ រូប និងមានអនុប្រធានមួយចំនួនជាជំនួយការដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋានត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ឌ.** និងជាអគ្គលេខាធិការ **គ.ស.ឌ.**។

**មាត្រា១៤ .-**

**គ.ស.ឌ.** មានត្រាដោយឡែក ដែលកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល សម្រាប់បំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

អគ្គលេខាធិការដ្ឋាន **គ.ស.ឌ.** មានសិទ្ធិប្រើត្រារបស់ **គ.ស.ឌ.** សម្រាប់បំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

## ជំពូកទី៥
## ប្រភពធនធានរបស់ គ.ស.ឌ.

**មាត្រា១៥ .-**

ការចំណាយសម្រាប់ដំណើរការការងាររបស់ **គ.ស.ឌ.** និងលេខាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋាន **គ.ស.ឌ.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិដាក់បញ្ចូលថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ **ក.ប.ឌ.**។

ការចំណាយសម្រាប់ដំណើរការការងាររបស់អង្គភាពសន្តិសុខសាយប័រកម្ពុជា ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិដាក់បញ្ចូលថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ **ក.ប.ឌ.**។

ការចំណាយសម្រាប់ដំណើរការការងាររបស់អង្គភាពប្រឆាំងឧក្រិដ្ឋកម្មសាយប័រ ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិដាក់បញ្ចូលថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ។

ការចំណាយសម្រាប់ដំណើរការការងាររបស់អង្គភាពការពារជាតិក្នុងលំហសាយប័រ ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិដាក់បញ្ចូលថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងការពារជាតិ។

ការចំណាយសម្រាប់ដំណើរការការងាររបស់អង្គភាពការទូតសាយប័រ ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិដាក់បញ្ចូលថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**គ.ស.ឌ.** មានសិទ្ធិទទួល គ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងថវិកាដៃគូអភិវឌ្ឍ ព្រមទាំងធនធាន ជាថវិកា និងទ្រព្យសម្បត្តិស្របច្បាប់ផ្សេងទៀត តាមនីតិវិធីច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន សម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា១៦ .-**

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជូន អនុប្រធានប្រចាំការ អនុប្រធាន និងសមាជិកនៃ **គ.ស.ឌ.** ត្រូវសម្រេចជាគោលការណ៍ដោយប្រមុខរាជរដ្ឋាភិបាល តាមសំណើរបស់អគ្គលេខាធិការនៃ **គ.ស.ឌ.**។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជូនថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន **គ.ស.ឌ.** ត្រូវសម្រេចដោយអគ្គលេខាធិការនៃ **គ.ស.ឌ.**។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ៦ រោច ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មីនា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...៤៤...... អនក្រ.បក ចុះថ្ងៃទី......១........ ខែ..មីនា....ឆ្នាំ២០២៤
ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសន្តិសុខឌីជីថល

**អង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសន្តិសុខឌីជីថល**



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# គុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការបង្កើតវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ កំណត់អំពីស្ថាប័នមានសមត្ថកិច្ច ប្រភេទមុខតំណែង លក្ខណវិនិច្ឆ័យគុណវុឌ្ឍិវិជ្ជាជីវៈ និងក្របខ័ណ្ឌសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ ដើម្បីពង្រឹងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈសំដៅចូលរួមចំណែកជានាប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ដែលមានភារកិច្ចអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**មាត្រា៣.-**

និយមន័យនៃវាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យស្តីពីគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈនេះ ត្រូវបានកំណត់ក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី២

## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសមត្ថកិច្ចកសាង ពង្រឹង និងត្រួតពិនិត្យគុណវុឌ្ឍិវិជ្ជាជីវៈសម្រាប់ការតែងតាំងឬការប្រគល់ភារកិច្ចជូនមន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបំពេញមុខងារជាសេនាធិការជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើការងារបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែងនិងការកសាងគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ។

**មាត្រា៥.-**

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល មានភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវលើការចាត់បញ្ជូនមន្ត្រី ស្របតាមលក្ខណវិនិច្ឆ័យដែលមានចែងក្នុងមាត្រា៨និងមាត្រា៩ នៃអនុក្រឹត្យនេះដើម្បីចូលរួមកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង
- រៀបចំកញ្ចប់ថវិកាផែនការកសាងនិងអភិវឌ្ឍសមត្ថភាពលើជំនាញហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំនីមួយៗ ដោយសហការជាមួយវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ផ្តល់ពេលវេលាគ្រប់គ្រាន់និងរក្សាបៀវត្ស អតីតភាពការងារសម្រាប់ការឡើងថ្នាក់ ឋានន្តរសក្តិ មុខតំណែង និងការចូលនិវត្តន៍ ព្រមទាំងរក្សាមុខតំណែងក្នុងអង្គភាពដើម ចំពោះមន្ត្រីដែលបានចាត់បញ្ជូនចូលរួមកម្មវិធីបណ្តុះបណ្តាល
- សហការផ្តល់ព័ត៌មាននិងទិន្នន័យមន្ត្រី ដែលត្រូវចូលរួមកម្មវិធីបណ្តុះបណ្តាល និងត្រួតពិនិត្យលើប្រសិទ្ធភាពនៃការបំពេញការងារក្រោយទទួលបានការបណ្តុះបណ្តាល។

**មាត្រា៦.-**

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវតែងតាំងឬប្រគល់ភារកិច្ចអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ ជូនដល់មន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈដែលមានគុណវុឌ្ឍិវិជ្ជាជីវៈ ស្របតាមការកំណត់ក្នុងមាត្រា៩ នៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## ប្រភេទមុខតំណែងការងារនិងលក្ខណវិនិច្ឆ័យ
## នៃមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ

**មាត្រា៧.-**

ប្រភេទមុខតំណែងការងារមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ មានដូចខាងក្រោម៖
- មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ
- មន្ត្រីនៃក្រុមការងារថវិកា
- រដ្ឋទេយ្យករបុរេប្រទាននិងរដ្ឋទេយ្យករបុរេប្រទានរង
- រដ្ឋទេយ្យករចំណូលនិងរដ្ឋទេយ្យករចំណូលរង
- មន្ត្រីនៃក្រុមលទ្ធកម្មនិងអង្គភាពលទ្ធកម្ម
- ភ្នាក់ងារបើកផ្តល់និងភ្នាក់ងារបើកផ្តល់ជំនួស
- មន្ត្រីគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- មន្ត្រីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល
- គណនេយ្យករគណនីពិសេសរតនាគារ
- គណនេយ្យករថវិកាឧបសម្ព័ន្ធ
- មន្ត្រីគ្រប់គ្រងការងារគម្រោងវិនិយោគសាធារណៈ
- មន្ត្រីគ្រប់គ្រងគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន
- មន្ត្រីផ្សេងទៀតទទួលបន្ទុកការងារហិរញ្ញវត្ថុសាធារណៈដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៨.-**

មន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈនិងមន្ត្រីពាក់ព័ន្ធ ដែលត្រូវចាត់ឱ្យចូលរួមកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង ត្រូវមានលក្ខណវិនិច្ឆ័យដូចខាងក្រោម៖

- ស្ថិតក្នុងមុខតំណែងឬត្រៀមទទួលមុខតំណែងពាក់ព័ន្ធនឹងការងារហិរញ្ញវត្ថុសាធារណៈ ដែលមិនទាន់មានគុណវុឌ្ឍិវិជ្ជាជីវៈតាមប្រភេទមុខតំណែងការងារនីមួយៗ
- មានលក្ខណសម្បត្តិល្អ ទទួលការវាយតម្លៃនិងការចាត់តាំងពីថ្នាក់ដឹកនាំអង្គភាព នៃក្រសួង ស្ថាប័នសាមី
- មានបទពិសោធឬចំណេះដឹងមូលដ្ឋានពាក់ព័ន្ធនឹង សេដ្ឋកិច្ច ហិរញ្ញវត្ថុ គណនេយ្យ ធនាគារ ការគ្រប់គ្រង ឬធុរកិច្ច រួមនឹងចំណេះដឹងចាំបាច់ក្នុងការប្រើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- មានឆន្ទៈនិងស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីចូលរួមវគ្គសិក្សាតាមកម្មវិធីបណ្តុះបណ្តាលដែលបានកំណត់។

មន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈនិងមន្ត្រីពាក់ព័ន្ធជាស្ត្រី ដែលមានលក្ខណវិនិច្ឆ័យដូចខាងលើ ត្រូវផ្តល់អាទិភាពឱ្យចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង។

## ជំពូកទី៤
## លក្ខខណ្ឌគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ

**មាត្រា៩.-**

ដើម្បីទទួលបានគុណវុឌ្ឍិវិជ្ជាជីវៈ មន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈនិងមន្ត្រីពាក់ព័ន្ធ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានវិញ្ញាបនបត្រជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- មានអាកប្បកិរិយាថ្លៃថ្នូរ ឆន្ទៈ ស្មារតីវិជ្ជាជីវៈ ការទទួលខុសត្រូវខ្ពស់ និងឥរិយាបថបំពេញការងារជាក្រុម ដែលបញ្ជាក់ដោយអង្គភាពនៃក្រសួង ស្ថាប័នសាមី
- ត្រូវចូលរួមវគ្គរំព្រឹកការនិងសុក្រឹតការក្នុងរយៈពេល៣ឆ្នាំម្តងឬតាមការចាំបាច់ ដើម្បីធ្វើបច្ចុប្បន្នកម្មចំណេះដឹងជំនាញ ចំពោះមន្ត្រីមានគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ។

ការតែងតាំងមុខតំណែងឬការប្រគល់ភារកិច្ចការងារពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ ត្រូវអនុលោមតាមមាត្រា១៨ នៃអនុក្រឹត្យនេះ។

**មាត្រា១០.-**

ឧទ្ទេសាចារ្យដែលត្រូវចូលរួមបង្ហាត់បង្រៀន ក្នុងកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែងប្រចាំនៅវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានកម្រិតសញ្ញាបត្រ ចាប់ពីបរិញ្ញាបត្រឡើងទៅលើជំនាញពាក់ព័ន្ធ
- មានបទពិសោធការងារយ៉ាងតិច៣ឆ្នាំក្នុងមុខងារពាក់ព័ន្ធមុខវិជ្ជាត្រូវបង្រៀន ឬមានវិញ្ញាបនបត្រកម្រិតទី៤ នៃកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង
- មានសមត្ថភាព ចំណេះដឹង ជំនាញឯកទេស និងទេពកោសល្យ លើមុខវិជ្ជាដែលត្រូវបង្រៀន
- មានសុខភាពល្អ អាកប្បកិរិយាថ្លៃថ្នូរ ឆន្ទៈ ស្មារតីវិជ្ជាជីវៈ និងការទទួលខុសត្រូវខ្ពស់

- ត្រូវចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របង្រៀន វគ្គវិក្រឹតការ ឬសុក្រឹតការលើមុខជំនាញពាក់ព័ន្ធ តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥
## ក្របខ័ណ្ឌសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ

**មាត្រា១១.-**

ក្របខ័ណ្ឌសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ មាន**៥កម្រិត** ដូចខាងក្រោម៖

- កម្រិតទី១ : សមត្ថភាពយល់ដឹងទូទៅ
- កម្រិតទី២ : សមត្ថភាពឯកទេសមូលដ្ឋាន
- កម្រិតទី៣ : សមត្ថភាពឯកទេសជំនាញ
- កម្រិតទី៤ : សមត្ថភាពឯកទេសជំនាញកម្រិតខ្ពស់
- កម្រិតទី៥ : សមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ក្របខ័ណ្ឌសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ ត្រូវកសាងនិងអភិវឌ្ឍតាមរយៈកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង។

**មាត្រា១២.-**

សមត្ថភាពយល់ដឹងទូទៅ ត្រូវកសាងនិងអភិវឌ្ឍតាមរយៈកម្មវិធីបណ្តុះបណ្តាលឯកទេសតម្រង់ទិស ដែលជាកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតទី១ ដើម្បីលើកកម្ពស់ការយល់ដឹងនិងចំណេះដឹងអំពីគោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ។

កម្មវិធីបណ្តុះបណ្តាលនេះ តម្រូវចំពោះមន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈនិងមន្ត្រីពាក់ព័ន្ធ។

**មាត្រា១៣.-**

សមត្ថភាពឯកទេសមូលដ្ឋាន ត្រូវកសាងនិងអភិវឌ្ឍតាមរយៈកម្មវិធីបណ្តុះបណ្តាលឯកទេសមូលដ្ឋាន ដែលជាកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតទី២ ដើម្បីបង្កើនសមត្ថភាព ចំណេះដឹង ការយល់ដឹង និងទេពកោសល្យ លើឯកទេសមូលដ្ឋានពាក់ព័ន្ធនឹងការងាររដ្ឋទេយ្យ ការងារបើកផ្តល់ ការងាររៀបចំរបាយការណ៍ កិច្ចបញ្ជិកាគណនេយ្យ បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ កិច្ចលទ្ធកម្មសាធារណៈ សវនកម្មផ្ទៃក្នុង និងការងារពាក់ព័ន្ធផ្សេងៗទៀត សម្រាប់អនុវត្តការងារហិរញ្ញវត្ថុសាធារណៈ។

កម្មវិធីបណ្តុះបណ្តាលនេះ តម្រូវចំពោះមន្ត្រីស្ថិតក្នុងមុខតំណែងឬត្រៀមទទួលមុខតំណែង ជារដ្ឋទេយ្យករបុរេប្រទានរង រដ្ឋទេយ្យករចំណូលរង ភ្នាក់ងារបើកផ្តល់ជំនួស ជំនួយការគណនេយ្យករ សមាជិកក្រុមការងារថវិកា សមាជិកគណៈកម្មការឬក្រុមការងារគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ សមាជិកគណៈកម្មាធិការលទ្ធកម្មឬសមាជិកក្រុមលទ្ធកម្ម សមាជិកគណៈកម្មការឬក្រុមការងារគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ជំនួយការគម្រោងវិនិយោគសាធារណៈ សមាជិកគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ជំនួយការថ្នាក់ដឹកនាំទទួលការងារពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងមន្ត្រីជំនាញពាក់ព័ន្ធ ដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលកម្រិតទី១។

**មាត្រា១៤.-**

សមត្ថភាពឯកទេសជំនាញ ត្រូវកសាងនិងអភិវឌ្ឍតាមរយៈកម្មវិធីបណ្តុះបណ្តាលឯកទេសជំនាញ ដែលជាកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតទី៣ ដើម្បីពង្រឹងពង្រីកសមត្ថភាព ចំណេះដឹង ឯកទេស និងទេពកោសល្យ លើជំនាញឯកទេសពាក់ព័ន្ធនឹងការងារថវិកា ការងាររជ្ជទេយ្យ ការងារបើកផ្តល់ ការងាររៀបចំរបាយការណ៍ កិច្ចបញ្ជិកាគណនេយ្យ បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ កិច្ចលទ្ធកម្មសាធារណៈ សវនកម្មផ្ទៃក្នុង និងការងារពាក់ព័ន្ធផ្សេងៗទៀត សម្រាប់អនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

កម្មវិធីបណ្តុះបណ្តាលនេះ តម្រូវចំពោះមន្ត្រីស្ថិតក្នុងមុខតំណែងឬត្រៀមទទួលមុខតំណែង ជារជ្ជទេយ្យករ ភ្នាក់ងារបើកផ្តល់ គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ អនុប្រធានគណៈកម្មការឬក្រុមការងារគ្រប់គ្រងបញ្ជីសារពើភណ្ឌ អនុប្រធានគណៈកម្មការឬក្រុមការងារគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ អនុប្រធានអង្គភាពលទ្ធកម្ម អនុប្រធានក្រុមលទ្ធកម្ម អនុប្រធានក្រុមការងារថវិកា អនុប្រធានអង្គភាពសវនកម្មផ្ទៃក្នុង អនុប្រធានគម្រោងវិនិយោគសាធារណៈ និងអនុប្រធានគ្រប់គ្រងគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលកម្រិតទី២។

**មាត្រា១៥.-**

សមត្ថភាពឯកទេសជំនាញកម្រិតខ្ពស់ ត្រូវកសាងនិងអភិវឌ្ឍតាមរយៈកម្មវិធីបណ្តុះបណ្តាលឯកទេសជំនាញកម្រិតខ្ពស់ដែលជាកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតទី៤ ដើម្បីអភិវឌ្ឍសមត្ថភាពជំនាញ និងទេពកោសល្យវិជ្ជាជីវៈ លើជំនាញបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងថវិកា លទ្ធកម្មសាធារណៈ គណនេយ្យសាធារណៈ សវនកម្មផ្ទៃក្នុង បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ការគ្រប់គ្រងគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន និងការងារពាក់ព័ន្ធផ្សេងៗទៀត សម្រាប់អនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

កម្មវិធីបណ្តុះបណ្តាលនេះមានលក្ខណៈពិសេស តម្រូវចំពោះមន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ ដែលមានតួនាទីចាប់ពីអនុប្រធាននាយកដ្ឋាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងនាយកទីចាត់ការហិរញ្ញវត្ថុ រាជធានី ខេត្ត សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬតួនាទីប្រហាក់ប្រហែលឡើងទៅ និងអតីតសិក្ខាកាម ដែលបញ្ចប់វគ្គបណ្តុះបណ្តាលកម្រិតទី៣។

**មាត្រា១៦.-**

សមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវកសាងនិងអភិវឌ្ឍតាមរយៈកម្មវិធីបណ្តុះបណ្តាលគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលជាកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតទី៥ ដើម្បីពង្រឹងពង្រីកការយល់ដឹង និងអភិវឌ្ឍសមត្ថភាព លើជំនាញពាក់ព័ន្ធនឹងគោលនយោបាយ សេដ្ឋកិច្ច ហិរញ្ញវត្ថុសាធារណៈ និងភាពជាអ្នកដឹកនាំនិងការគ្រប់គ្រងការផ្លាស់ប្តូរ ជាដើម សំដៅធានាប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយនិងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

កម្មវិធីបណ្តុះបណ្តាលនេះមានលក្ខណៈពិសេស តម្រូវចំពោះថ្នាក់ដឹកនាំដែលមានតួនាទីចាប់ពីអគ្គនាយករង សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងអភិបាលរងរាជធានី ខេត្ត សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬតួនាទីប្រហាក់ប្រហែលឡើងទៅ និងអតីតសិក្ខាកាមដែលបញ្ចប់វគ្គបណ្តុះបណ្តាលកម្រិតទី៤។

**មាត្រា១៧.-**

មន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈនិងមន្ត្រីពាក់ព័ន្ធ ដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលកម្រិតទី១ដោយជោគជ័យ អាចបន្តចូលរួមវគ្គបណ្តុះបណ្តាលកម្រិតទី២និងកម្រិតបន្តបន្ទាប់។

**មាត្រា១៨.-**

ក្របខ័ណ្ឌសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈកម្រិតទី២ កម្រិតទី៣ និងកម្រិតទី៤ គឺជាមូលដ្ឋាន សម្រាប់ការតែងតាំងមុខតំណែងឬការប្រគល់ភារកិច្ចការងារពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា១៩.-**

ការបណ្តុះបណ្តាលកម្រិតទី១ កម្រិតទី២ និងកម្រិតទី៣ ដូចមានកំណត់ក្នុងមាត្រា១២ មាត្រា១៣ និងមាត្រា១៤ខាងលើ ពុំមែនជាកាតព្វកិច្ច ចំពោះមន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ ដែលមានតួនាទីចាប់ពីអនុប្រធាននាយកដ្ឋាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងនាយកទីចាត់ការហិរញ្ញវត្ថុ រាជធានីខេត្ត សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬតួនាទីប្រហាក់ប្រហែលឡើងទៅ។

## ជំពូកទី៦

## បន្ទុកចំណាយនិងថ្លៃសេវា

**មាត្រា២០.-**

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរ៉ាប់រងការចំណាយនិងការបង់ថ្លៃចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង សម្រាប់មន្ត្រីរបស់ខ្លួន។

**មាត្រា២១.-**

ថ្លៃសេវាបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៧

## ការលើកទឹកចិត្តនិងទណ្ឌកម្ម

### ផ្នែកទី១

### ការលើកទឹកចិត្ត

**មាត្រា២២.-**

ក្រោយបញ្ចប់ការបណ្តុះបណ្តាលដោយជោគជ័យ សិក្ខាកាមទទួលបាន៖

- វិញ្ញាបនបត្របញ្ជាក់ការសិក្សា ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ ជាមូលដ្ឋាននៃការតែងតាំងមុខតំណែងឬការប្រគល់ភារកិច្ចពាក់ព័ន្ធនឹងការងារហិរញ្ញវត្ថុសាធារណៈ តាមកម្រិតសមត្ថភាពនីមួយៗ

- អាទិភាពក្នុងការវាយតម្លៃសម្រាប់ដំឡើងថ្នាក់តាមវេនប្រចាំឆ្នាំ ក្រោយបញ្ចប់ការបណ្ដុះបណ្ដាលដោយជោគជ័យនៅកម្រិតទី៤ នៃជំនាញនីមួយៗចំពោះសិក្ខាកាមជាមន្ត្រីរាជការ
- អាទិភាពក្នុងការជ្រើសរើសជាគ្រូបង្គោល ក្រោយបញ្ចប់ការបណ្ដុះបណ្ដាលដោយជោគជ័យនៅកម្រិតទី៤ នៃជំនាញនីមួយៗ។

**មាត្រា២៣.-**

ឧទ្ទេសាចារ្យដែលមានស្នាដៃល្អក្នុងការបង្ហាត់បង្រៀន ទទួលបាន៖

- ការផ្ដល់ឋានៈឧទ្ទេសាចារ្យ ប្រចាំនៅវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រឿងឥស្សរិយយសឬបណ្ណសរសើរ
- ឱកាសចូលរួមទស្សនកិច្ចសិក្សា សិក្ខាសាលា សន្និសីទ និងកម្មវិធីបណ្ដុះបណ្ដាលក្រៅប្រទេស
- ការលើកទឹកចិត្តនិងអត្ថប្រយោជន៍ផ្សេងទៀត តាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គោលការណ៍ ប្រភេទ និងនីតិវិធីនៃការផ្ដល់ឋានៈឧទ្ទេសាចារ្យ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៤.-**

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលបានចាត់បញ្ជូនមន្ត្រីចូលរួមវគ្គបណ្ដុះបណ្ដាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង ទទួលបាន៖

- ការគាំទ្រជាអាទិភាពលើការកសាងនិងអភិវឌ្ឍសមត្ថភាពជំនាញគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ការលើកទឹកចិត្តផ្សេងទៀត តាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី២

## ទណ្ឌកម្ម

**មាត្រា២៥.-**

ក្រោយរយៈពេល៣ឆ្នាំបន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន មន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈដែលគ្មានវិញ្ញាបនបត្រពីកម្មវិធីបណ្ដុះបណ្ដាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង ត្រូវផ្លាស់ប្ដូរឬជំនួសដោយមន្ត្រីមានគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈតាមប្រភេទមុខតំណែងការងារនីមួយៗ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា២៦.-**

មន្ត្រីដែលត្រូវបានចាត់ឱ្យចូលរួមវគ្គបណ្ដុះបណ្ដាល និងមិនបានបំពេញតាមលក្ខខណ្ឌកំណត់នៃកម្មវិធីបណ្ដុះបណ្ដាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង ត្រូវជាកម្មវត្ថុដូចខាងក្រោម៖

- មិនអនុញ្ញាតឱ្យប្រឡងបញ្ចប់ការសិក្សា
- មិនមានសិទ្ធិទទួលវិញ្ញាបនបត្របញ្ជាក់ការសិក្សា
- មិនទទួលបានគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ

- មិនទទួលបានការតែងតាំងមុខតំណែងឬការប្រគល់ភារកិច្ចពាក់ព័ន្ធការងារហិរញ្ញវត្ថុសាធារណៈ
- មិនអនុញ្ញាតឱ្យបន្តចូលរួមកម្មវិធីបណ្តុះបណ្តាលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៧.-**

ឧទ្ទេសាចារ្យដែលមិនបានអនុវត្តតាមលក្ខខណ្ឌកំណត់ក្នុងកម្មវិធីបណ្តុះបណ្តាល ត្រូវទទួលទណ្ឌកម្មដូចខាងក្រោម៖

- ផ្អាកការបង្រៀនរហូតដល់មានការកែលម្អតាមលក្ខខណ្ឌកំណត់ក្នុងកម្មវិធីបណ្តុះបណ្តាល
- ជូនដំណឹងឬផ្តល់ការណែនាំជាលាយលក្ខណ៍អក្សរ
- បាត់បង់ឱកាសទទួលបានឋានៈឧទ្ទេសាចារ្យ ប្រចាំនៅវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៨.-**

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមិនអនុវត្តតាមអនុក្រឹត្យនេះ ជាកម្មវត្ថុនៃការមិនទទួលបានការគាំទ្រលើការស្នើតែងតាំង ឬការប្រគល់ភារកិច្ចដល់មន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ។

## ជំពូកទី៨
## ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**មាត្រា២៩.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ ត្រូវតាមដានត្រួតពិនិត្យ និងវាយតម្លៃតម្រូវការ គុណភាព និងប្រសិទ្ធភាពនៃកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង។

**មាត្រា៣០.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ ត្រូវផ្ទៀងផ្ទាត់អនុលោមភាពលើការតែងតាំងឬការផ្លាស់ប្តូរមុខតំណែង និងការប្រគល់ភារកិច្ចជូនមន្ត្រីដែលមានគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ សម្រាប់អនុវត្តការងារហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។

## ជំពូកទី៩
## អន្តរប្បញ្ញត្តិ

**មាត្រា៣១.-**

វិញ្ញាបនបត្របញ្ជាក់ការសិក្សាពីកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលបានចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវសមមូលនឹងវិញ្ញាបនបត្រកម្រិតទី២នៃកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង ដូចមានចែងក្នុងមាត្រា១៣ នៃអនុក្រឹត្យនេះ។

ក្រោយអនុក្រឹត្យនេះចូលជាធរមាន មន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈដែលមិនមានគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ ស្របតាមប្រភេទមុខតំណែងការងារនីមួយៗ ត្រូវចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង។

## ជំពូកទី១០
## អវសានប្បញ្ញត្តិ

**មាត្រា៣២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែលដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ២ កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...៤៥.....អនក្រ.បក ចុះថ្ងៃទី ..១១.. ខែ .មីនា.... ឆ្នាំ២០២៤
## ស្តីពីគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ
## សទ្ទានុក្រម

វាក្យសព្ទដែលបានប្រើក្នុងអនុក្រឹត្យស្តីពីគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ ត្រូវបានកំណត់និយមន័យដូចតទៅ៖

**ក្របខ័ណ្ឌសមត្ថភាព** សំដៅដល់កម្រិតសមត្ថភាពដែលត្រូវបានកំណត់តាមជំនាញនិងប្រភេទមុខតំណែងរបស់មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ។

**ការអភិវឌ្ឍគុណវុឌ្ឍិវិជ្ជាជីវៈ** សំដៅដល់ដំណើរការរៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលសម្រាប់បំពាក់គុណវុឌ្ឍិវិជ្ជាជីវៈផ្សារភ្ជាប់មុខតំណែង តាមរយៈវិញ្ញាបនបត្របញ្ជាក់លទ្ធផលសិក្សា ដើម្បីអនុវត្តតួនាទី ភារកិច្ចប្រកបដោយវិជ្ជាជីវៈឆ្លើយតបទៅនឹងស្តង់ដាប្រតិបត្តិ និងជានាប្រសិទ្ធភាពការងារ។

**គណនេយ្យករថវិកាឧបសម្ព័ន្ធ** សំដៅដល់ភ្នាក់ងាររបស់រដ្ឋដែលទទួលបន្ទុកលើកិច្ចការទទួលនិងគ្រប់គ្រងចំណូល ទូទាត់ចំណាយ រក្សាទុកដាក់និងគ្រប់គ្រងសាច់ប្រាក់ កាន់បញ្ជីគណនេយ្យ និងរៀបចំរបាយការណ៍ថវិកានិងហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនឹងការអនុវត្តថវិកាឧបសម្ព័ន្ធទាំងនៅថ្នាក់ជាតិ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ គណនេយ្យករថវិកាឧបសម្ព័ន្ធ ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ។

**គុណវុឌ្ឍិវិជ្ជាជីវៈ** សំដៅដល់បណ្តុំសមត្ថភាព ជំនាញវិជ្ជាជីវៈ និងទេពកោសល្យ ដែលឆ្លើយតបទៅនឹងមុខតំណែង តួនាទី និងភារកិច្ចសំខាន់ៗនៅតាមអង្គភាពការងារ។

**គុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ** សំដៅដល់គុណវុឌ្ឍិវិជ្ជាជីវៈ ដែលទទួលបានតាមរយៈការបណ្តុះបណ្តាលជំនាញហិរញ្ញវត្ថុសាធារណៈ ពីកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង។

**គណនេយ្យករគណនីពិសេសរតនាគារ** សំដៅដល់ភ្នាក់ងាររបស់រដ្ឋដែលទទួលបន្ទុកលើកិច្ចការទទួលនិងគ្រប់គ្រងចំណូល ទូទាត់ចំណាយ រក្សាទុកដាក់និងគ្រប់គ្រងសាច់ប្រាក់ កាន់បញ្ជីគណនេយ្យ និងរៀបចំរបាយការណ៍ថវិកានិងហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនឹងការអនុវត្តគណនីពិសេសរតនាគារ។ គណនេយ្យករគណនីពិសេសរតនាគារ ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ។

**ឧទ្ទេសាចារ្យ** សំដៅដល់មន្ត្រីរាជការឬមន្ត្រីចូលនិវត្តន៍ ឬក៏អ្នកជំនាញ ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដូចការកំណត់ក្នុងមាត្រា១០ នៃអនុក្រឹត្យនេះ និងមានមុខងាររៀបចំកម្មវិធី ឯកសារមេរៀន និងជាអ្នកបង្ហាត់បង្រៀន ប្រចាំនៅវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ភ្នាក់ងារបើកផ្តល់** សំដៅដល់អ្នកបើកបៀវត្សនិងលាភការផ្សេងៗរបស់បុគ្គលិកនិងមន្ត្រីរាជការ។

**មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ** សំដៅដល់មន្ត្រីរាជការដែលមានភារកិច្ចអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ និងដែលមានគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈតាមប្រភេទមុខតំណែងការងារនីមួយៗ។

**មន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ** សំដៅដល់មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា មន្ត្រីលក្ខន្តិកៈ ឬបុគ្គលិកជាប់កិច្ចសន្យា ដែលមានភារកិច្ចអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ ប៉ុន្តែមិនទាន់ទទួលគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈតាមប្រភេទមុខតំណែងការងារនីមួយៗ។

**មន្ត្រីមានគុណវុឌ្ឍិវិជ្ជាជីវៈហិរញ្ញវត្ថុសាធារណៈ** សំដៅដល់មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា មន្ត្រីលក្ខន្តិកៈ ឬបុគ្គលិកជាប់កិច្ចសន្យា ដែលបានទទួលការបណ្តុះបណ្តាលជំនាញហិរញ្ញវត្ថុសាធារណៈ ពីកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង។

**មន្ត្រីពាក់ព័ន្ធ** សំដៅដល់មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា មន្ត្រីលក្ខន្តិកៈ ឬបុគ្គលិកជាប់កិច្ចសន្យាដែលមានតម្រូវការបណ្តុះបណ្តាលជំនាញហិរញ្ញវត្ថុសាធារណៈពីកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង។

**មន្ត្រីគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ** សំដៅដល់មន្ត្រីដែលទទួលបន្ទុកអនុវត្តការងារគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពថវិកា។

**មន្ត្រីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ** សំដៅដល់មន្ត្រីដែលទទួលបន្ទុកអនុវត្តការងារគ្រប់គ្រងចំណូលមិនមែនសារពើពន្ធរបស់អង្គភាពថវិកា។

**មន្ត្រីគ្រប់គ្រងការងារគម្រោងវិនិយោគសាធារណៈ** សំដៅដល់មន្ត្រីដែលទទួលបន្ទុកអនុវត្តការងារគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។

**មន្ត្រីគ្រប់គ្រងការងារគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន** សំដៅដល់មន្ត្រីដែលទទួលបន្ទុកអនុវត្តការងារគ្រប់គ្រងគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន។

**មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ** សំដៅដល់មន្ត្រីជាសេនាធិការរបស់ប្រធានអង្គភាពថវិកា ដែលត្រូវអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ដោយត្រូវគោរពតាមវិធាននិងបទប្បញ្ញត្តិហិរញ្ញវត្ថុជាធរមាន។

**មន្ត្រីនៃក្រុមលទ្ធកម្ម** សំដៅដល់មន្ត្រីដែលមានភារកិច្ចជាប្រធាន អនុប្រធាន ឬសមាជិកនៃក្រុមលទ្ធកម្ម។

៥- ទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវធ្វើការណែនាំអំពីទម្រង់របាយការណ៍សម្រាប់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ធ្វើការបូកសរុបរាយការណ៍អំពីសកម្មភាពនិងលទ្ធផលការងារចុះមូលដ្ឋាន និងរៀបចំឯកសារណែនាំសម្រាប់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានសហការរៀបចំវេទិកាសាធារណៈ ដើម្បីសហការជំរុញការដោះស្រាយឆ្លើយតបបញ្ហាប្រឈមនានានៅមូលដ្ឋានប្រកបដោយប្រសិទ្ធភាព។

ទទួលបានសេចក្តីណែនាំនេះ ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ត្រូវសហការចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ សុក្រ ៦រោច ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មីនា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ០៦៦ ........សហវ.ប្រក.អថ

**ប្រកាស**

**ស្តីពី**

**ការបង្កើត និងការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពត្រួតពិនិត្យថវិកា នៅអមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- ប្រកាសលេខ ០៦២ សហវ.ប្រក.អថ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០២៤ ស្តីពីសិទ្ធិអំណាចនិងការទទួលខុសត្រូវរបស់អគ្គិបាលថវិកា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia



ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

## សម្រេច

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ត្រូវបានបង្កើតអង្គភាពត្រួតពិនិត្យថវិកា សរសេរជាអក្សរកាត់ "អ.ត.ថ." ឱ្យនៅអមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ដើម្បីបំពេញមុខងារត្រួតពិនិត្យការអនុវត្តថវិកា ។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់អង្គភាពត្រួតពិនិត្យថវិកា ដែលនៅអមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ។

### ជំពូកទី ២
### រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច

**ប្រការ៣.-**

អ.ត.ថ. ត្រូវស្ថិតក្រោមការគ្រប់គ្រងមុខងាររបស់នាយកដ្ឋានហិរញ្ញកិច្ចនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

អ.ត.ថ. ត្រូវដឹកនាំដោយប្រធាន ១ (មួយ) រូប ដែលមានឋានៈនិងបុព្វសិទ្ធិស្មើនឹងអនុប្រធាននាយកដ្ឋាន និងអាចមានអនុប្រធានមួយចំនួនតាមការចាំបាច់ ដែលមានឋានៈនិងបុព្វសិទ្ធិស្មើនឹងប្រធានការិយាល័យ ។

ប្រធាន និងអនុប្រធាន ព្រមទាំងមន្ត្រី នៃ អ.ត.ថ. ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ៤.-**

អ.ត.ថ. មានតួនាទីនិងភារកិច្ចដូចតទៅ ៖

- ត្រួតពិនិត្យនិងតាមដានការអនុវត្តចំណាយចរន្តឱ្យស្របតាមបទប្បញ្ញត្តិជាធរមាន
- តាមដាននិងជំរុញការអនុវត្តចំណូលមិនមែនសារពើពន្ធ ស្របតាមបទប្បញ្ញត្តិជាធរមាន
- ផ្តល់យោបល់និងជំរុញក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទ ក្នុងការអនុវត្តនីតិវិធីហិរញ្ញវត្ថុ ក្នុងគោលបំណងគោរពឱ្យបានហ្មត់ចត់នូវគោលការណ៍និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងវិន័យថវិកាក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាធរមាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពជំនាញវិជ្ជាជីវៈ និងប្រសិទ្ធភាពចំណាយ
- ផ្តល់ទិដ្ឋាការធានាចំណាយ និងអាណត្តិបើកប្រាក់ទៅតាមមុខសញ្ញាចំណាយ តាមកម្រិតទឹកប្រាក់ដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រគល់សិទ្ធិ
- រៀបចំផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ និងសម្រេច លើសំណើចំណាយសម្រាប់មុខសញ្ញាចំណាយដែលមិនស្ថិតក្រោមសិទ្ធិ និងការទទួលខុសត្រូវរបស់ខ្លួន
- ផ្តល់យោបល់លើកម្មវិធីចំណូល-ចំណាយ និងការអនុវត្តសមិទ្ធកម្ម របស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល
- ពិនិត្យ និងតាមដានរបាយការណ៍អនុវត្តថវិកា (ចំណូល-ចំណាយ) និងរបាយការណ៍សមិទ្ធកម្មដែលរៀបចំដោយក្រសួង ស្ថាប័នសាមី



kr

- ចូលរួមរៀបចំផែនការយុទ្ធសាស្ត្រថវិការយៈពេលមធ្យម និងផែនការថវិកាប្រចាំឆ្នាំ
- ជានាអនុលោមភាពការអនុវត្តថវិកាជាមួយនឹងស្មារតីនៃកិច្ចប្រជុំការពារគម្រោងថវិកាប្រចាំឆ្នាំ
- ពិនិត្យនិងផ្តល់យោបល់លើការស្នើសុំចលនាឥណទាន
- ចូលរួមក្នុងកិច្ចប្រគល់-ទទួលទំនិញ សម្ភារៈ បរិក្ខារ សេវា និងសំណង់ តាមនីតិវិធីជាធរមាន
- រៀបចំរបាយការណ៍អនុវត្តថវិកា (ចំណូល-ចំណាយ) ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ របស់ក្រសួង ស្ថាប័នទទួលបន្ទុក តាមគំរូ ដោយផ្ទៀងផ្ទាត់តួលេខឱ្យបានត្រឹមត្រូវជាមួយសាមីក្រសួង ស្ថាប័ន ព្រមទាំងរៀបចំរបាយការណ៍សកម្មភាពរបស់ខ្លួន ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមឋានានុក្រម
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ជំពូកទី ៣
## របៀបរបបការងារ

**ប្រការ៥.-**

អ.ត.ថ. ពិនិត្យសំណើសុំចំណាយរបស់ក្រសួង ស្ថាប័ន ទៅតាមមុខសញ្ញាចំណាយ និងតាមកម្រិតទឹកប្រាក់ តាមការប្រគល់សិទ្ធិពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងផ្តល់យោបល់ឱ្យបានសមហេតុផលជាលាយលក្ខណ៍អក្សរ តាមរយៈកំណត់បង្ហាញរឿង ដូចតទៅ ៖

១- ពិនិត្យនិងផ្តល់យោបល់ ព្រមទាំងផ្តល់ទិដ្ឋាការជានាចំណាយ និង/ឬអាណត្តិបើកប្រាក់ ក្នុងរយៈពេលយ៉ាងយូរ៣ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីបញ្ជាក់ពីការយល់ព្រមឱ្យអនុវត្តចំណាយ ដោយអនុលោមវិធាននិងនីតិវិធីហិរញ្ញវត្ថុជាធរមាន ។ ក្នុងករណីពិនិត្យឃើញថាសំណើចំណាយមានវេទយិតភាព មន្ត្រីត្រួតពិនិត្យថវិកាត្រូវស្នើសុំការសម្រេចពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមឋានានុក្រម ។

២- ក្នុងករណីពិនិត្យឃើញមានកំហុសឆ្គង ឬភាពមិនច្បាស់លាស់ អ.ត.ថ. ត្រូវស្នើសុំការកែតម្រូវ ការបញ្ជាក់ ឬការពន្យល់បន្ថែមពីសាមីក្រសួង ស្ថាប័ន ។ ប្រសិនបើការកែតម្រូវ ការបញ្ជាក់ ឬការពន្យល់អាចដោះស្រាយបាននូវបញ្ហាខុសឆ្គង ឬភាពមិនច្បាស់លាស់ អ.ត.ថ. ត្រូវអនុវត្តតាមចំណុចទី១ ខាងលើ ។ ក្នុងករណីការកែតម្រូវ ការបញ្ជាក់ ឬការពន្យល់បន្ថែមនេះ នៅតែមិនអាចឆ្លើយតបនឹងតម្រូវការទេ នោះ អ.ត.ថ. ត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរអំពីការខ្វះខាតទាំងនោះ និងបញ្ជាក់អំពីការមិនយល់ព្រម និងមូលហេតុ ដើម្បីបញ្ជូនត្រឡប់ទៅសាមីក្រសួង ស្ថាប័នវិញ ព្រមទាំងត្រូវធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមឋានានុក្រម ។

**ប្រការ៦.-**

អ.ត.ថ. ពិនិត្យសំណើសុំចំណាយរបស់ក្រសួង ស្ថាប័ន ដែលមានទឹកប្រាក់ធំជាងកម្រិតទឹកប្រាក់ដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានប្រគល់សិទ្ធិ ដោយត្រូវផ្តល់យោបល់ឱ្យបានត្រឹមត្រូវជាលាយលក្ខណ៍អក្សរ ដើម្បីសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមឋានានុក្រម ។ រាល់ឯកសារដែលបញ្ជូនមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវមានសក្ខីបត្រភ្ជាប់គ្រប់គ្រាន់ និងត្រឹមត្រូវ ។

**ប្រការ៧.-**

អ.ត.ថ. ពិនិត្យនិងផ្តល់យោបល់លើកម្មវិធីចំណូល-ចំណាយ និងសំណើសុំនិយ័តភាពថវិការបស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ក្នុងរយៈពេលបី (៣) ថ្ងៃនៃថ្ងៃធ្វើការ រួចបញ្ជូនទៅក្រសួង ស្ថាប័ន

និងអង្គភាពសាមី និងទៅនាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីមុខការបន្ត តាមការប្រគល់សិទ្ធិ ស្របតាមបទប្បញ្ញត្តិជាធរមាន ។

**ប្រការ៨.-**

អ.គ.ថ. ត្រូវរៀបចំរបាយការណ៍អនុវត្តថវិកា(ចំណូល-ចំណាយ), របាយការណ៍ផ្តល់ទិដ្ឋាការ ឬមិនផ្តល់ទិដ្ឋាការ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ របស់ក្រសួង ស្ថាប័ន ទទួលបន្ទុក តាមគំរូ និងពេលវេលាកំណត់ដោយបទដ្ឋានគតិយុត្តពាក់ព័ន្ធ ព្រមទាំងរបាយការណ៍ផ្សេងទៀតតាមការចាំបាច់ ។

## ជំពូកទី ៤
## សិទ្ធិអំណាច និងការទទួលខុសត្រូវ

**ប្រការ៩.-**

ប្រធាន អ.គ.ថ. អាចទទួលបានការប្រគល់សិទ្ធិជាអភិបាលថវិកាពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ប្រធាន អ.គ.ថ. ត្រូវប្រគល់សិទ្ធិជូនអនុប្រធានមួយរូបជាអភិបាលថវិកា ដើម្បីចាត់ចែងការងារ និងចុះហត្ថលេខាលើលិខិតផ្លូវការទាំងឡាយ ក្នុងករណីអវត្តមានឬមានធុរៈ ដោយមានការឯកភាពពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានានិរន្តរភាពការងាររបស់ អ.គ.ថ. ។

ប្រធាន អ.គ.ថ. ត្រូវទទួលខុសត្រូវចំពោះមុខរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវរាល់កិច្ចការរបស់ខ្លួន ។

**ប្រការ១០.-**

សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់ប្រធាន អ.គ.ថ. និងការប្រគល់សិទ្ធិជាអភិបាលថវិកា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ១១.-**

ក្នុងការបំពេញមុខងារដូចមានកំណត់ក្នុងប្រការ៩ និងប្រការ១០ នៃប្រកាសនេះ ប្រធាន អ.គ.ថ. មានសិទ្ធិប្រើប្រាស់ត្រាអភិបាលថវិកា ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ច ។

## ជំពូកទី ៥
## ការលើកទឹកចិត្ត និងទណ្ឌកម្ម

**ប្រការ១២.-**

មន្ត្រីនៃ អ.គ.ថ. គ្រប់ឋានៈត្រូវទទួលបានការសរសើរ ចំពោះស្នាដៃជាគំរូក្នុងការបំពេញភារកិច្ចបានប្រសើរ ដោយផ្តល់ជាបណ្ណសរសើរ មេដាយ រង្វាន់ ឬដំឡើងថ្នាក់ ឋានន្តរស័ក្តិ ។ល។

**ប្រការ១៣.-**

មន្ត្រីនៃ អ.គ.ថ. គ្រប់ឋានៈត្រូវទទួលទណ្ឌកម្មរដ្ឋបាលតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដោយមិនទាន់គិតដល់ទណ្ឌកម្មព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងៗ ចំពោះសកម្មភាពដែលបានប្រព្រឹត្ត ឬសមគំនិតក្នុងការប្រព្រឹត្ត ។ ទណ្ឌកម្មរដ្ឋបាលទាំងនេះ មានដូចខាងក្រោម៖

- ការស្តីបន្ទោស
- ការផ្លាស់កន្លែងធ្វើការដោយបង្ខំតាមវិធានការខាងវិន័យ

- ការលុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់
- ការដាក់ឱ្យនៅទំនេរគ្មានបៀវត្ស
- ការបន្ថយឋានន្តរស័ក្តិ ឬថ្នាក់
- ការដាក់ឱ្យចូលនិវត្តន៍មុនកាលកំណត់
- ការបញ្ឈប់ពីការងារដោយបង្ខំ ឬការបណ្តេញចេញពីមុខតំណែងជាមន្ត្រីរាជការ ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**ប្រការ១៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ១៥.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាននិង ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ពុធ ១៤កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ១៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១១៥ សហវ.ប្រកា.១៣៧ទ

# ប្រកាស
# ស្តីពី
# ការលើកទឹកចិត្តពន្ធដារចំពោះសហគ្រាសក្នុងវិស័យទេសចរណ៍

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

## សម្រេច

### ប្រការ១ ._ គោលបំណង

ប្រកាសនេះ មានគោលបំណងផ្តល់ការលើកទឹកចិត្តពន្ធដារដល់សហគ្រាសក្នុងវិស័យទេសចរណ៍ ស្របតាមវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល ដើម្បីជួយស្តារវិស័យទេសចរណ៍ឱ្យបានល្អប្រសើរឡើងវិញ។

### ប្រការ២ ._ វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះសហគ្រាសក្នុងវិស័យទេសចរណ៍រួមមាន សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ដែលបានចុះបញ្ជីពន្ធដារ និងមានសកម្មភាពអាជីវកម្មស្ថិតនៅរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តកែប និងខេត្តកំពត។

### ប្រការ៣ ._ ការលើកទឹកចិត្តពន្ធដារ

១. ចំពោះសហគ្រាសក្នុងវិស័យទេសចរណ៍រួមមាន សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ដែលស្ថិតនៅខេត្តសៀមរាប ត្រូវទទួលបានការលើកទឹកចិត្តពន្ធដារ ដូចខាងក្រោម៖

ក. លើកលែងការបង់ពន្ធអាករប្រចាំខែគ្រប់ប្រភេទ វៀរលែងតែអាករលើតម្លៃបន្ថែម និងអាករលើការស្នាក់នៅ គិតចាប់ពីខែតុលា ឆ្នាំ២០២៣ រហូតដល់ដំណាច់ខែមិថុនា ឆ្នាំ២០២៤។

ខ. លើកលែងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០២៣។ ចំពោះប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលសហគ្រាសបានបង់រួច នឹងត្រូវបានអនុញ្ញាតជាឥណទានពន្ធសម្រាប់កាត់កងជាមួយពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០២៤។

គ. លើកលែងបំណុលពន្ធទាំងអស់ ដែលមានការិយបរិច្ឆេទមុនឆ្នាំ២០២៣ ដែលក្នុងនោះរួមមានប្រាក់ពន្ធ ពន្ធបន្ថែម ការប្រាក់ ពន្ធបន្ថែម២៥% និងការប្រាក់រត់បន្ត។

ឃ. មិនទទួលរងការធ្វើសវនកម្មពន្ធដារ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២០ ដល់ឆ្នាំ២០២៣។

២. ចំពោះសហគ្រាសក្នុងវិស័យទេសចរណ៍រួមមាន សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ដែលស្ថិតនៅរាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តកែប និងខេត្តកំពត ត្រូវទទួលបានការលើកលែងដោយមិនទទួលរងការធ្វើសវនកម្មពន្ធដារ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២០ ដល់ឆ្នាំ២០២២។

### ប្រការ៤ ._ កាតព្វកិច្ចដាក់លិខិតប្រកាសពន្ធ និងការរក្សាទុកបញ្ជីគណនេយ្យ

ក្នុងអំឡុងពេលនៃការលើកទឹកចិត្តដូចមានចែងក្នុងប្រការ៣ នៃប្រកាសនេះ សហគ្រាសនៅតែមានកាតព្វកិច្ចដូចខាងក្រោម៖

១. អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ ត្រូវដាក់លិខិតប្រកាសពន្ធអាករដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មអនឡាញ (e-Filing) ជារៀងរាល់ខែ និងត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់

**ប្រការ៥ .- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .- ការអនុវត្តប្រកាស**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១៣រោច ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៤០ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលរបស់សហគ្រាសឧស្សាហកម្ម ផ្នែកវាយនភណ្ឌកាត់ដេរ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia



ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

សម្រេច

**ប្រការ១ ._ គោលបំណង**

ប្រកាសនេះ មានគោលបំណងផ្ដល់ការលើកទឹកចិត្តពន្ធដារដល់សហគ្រាសក្នុងវិស័យទេសចរណ៍ ស្របតាមផែនការអន្តរាគមន៍របស់រាជរដ្ឋាភិបាល ដើម្បីជួយស្តារវិស័យទេសចរណ៍ឱ្យបានល្អប្រសើរឡើងវិញ។

**ប្រការ២ ._ វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះសហគ្រាសក្នុងវិស័យទេសចរណ៍រួមមាន សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ដែលបានចុះបញ្ជីពន្ធដារ និងមានសកម្មភាពអាជីវកម្មស្ថិតនៅរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តកែប និងខេត្តកំពត។

**ប្រការ៣ ._ ការលើកទឹកចិត្តពន្ធដារ**

១. ចំពោះសហគ្រាសក្នុងវិស័យទេសចរណ៍រួមមាន សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ដែលស្ថិតនៅខេត្តសៀមរាប ត្រូវទទួលបានការលើកទឹកចិត្តពន្ធដារ ដូចខាងក្រោម៖

ក. លើកលែងការបង់ពន្ធអាករប្រចាំខែគ្រប់ប្រភេទ វៀរលែងតែអាករលើតម្លៃបន្ថែម និងអាករលើការស្នាក់នៅ គិតចាប់ពីខែតុលា ឆ្នាំ២០២៣ រហូតដល់ដំណាច់ខែមិថុនា ឆ្នាំ២០២៤។

ខ. លើកលែងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០២៣។ ចំពោះប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលសហគ្រាសបានបង់រួច នឹងត្រូវបានអនុញ្ញាតជាឥណទានពន្ធសម្រាប់កាត់កងជាមួយពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០២៤។

គ. លើកលែងបំណុលពន្ធទាំងអស់ ដែលមានការិយបរិច្ឆេទមុនឆ្នាំ២០២៣ ដែលក្នុងនោះរួមមានប្រាក់ពន្ធ ពន្ធបន្ថែម ការប្រាក់ ពន្ធបន្ថែម២៥% និងការប្រាក់រត់បន្ត។

ឃ. មិនទទួលរងការធ្វើសវនកម្មពន្ធដារ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២០ ដល់ឆ្នាំ២០២៣។

២. ចំពោះសហគ្រាសក្នុងវិស័យទេសចរណ៍រួមមាន សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ដែលស្ថិតនៅរាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តកែប និងខេត្តកំពត ត្រូវទទួលបានការលើកលែងដោយមិនទទួលរងការធ្វើសវនកម្មពន្ធដារ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២០ ដល់ឆ្នាំ២០២២។

**ប្រការ៤ ._ កាតព្វកិច្ចដាក់លិខិតប្រកាសពន្ធ និងកាន់បញ្ជីគណនេយ្យ**

ក្នុងអំឡុងពេលនៃការលើកទឹកចិត្តដូចមានចែងក្នុងប្រការ៣ នៃប្រកាសនេះ សហគ្រាសនៅតែមានកាតព្វកិច្ចដូចខាងក្រោម៖

១. អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ ត្រូវដាក់លិខិតប្រកាសពន្ធអាករដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មអនឡាញ (e-Filing) ជារៀងរាល់ខែ និងត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់

**ប្រការ៥ ._ និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ ._ ការអនុវត្តប្រកាស**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មករា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៥ សហវ.គណ៧.ឌ.បគហ

# សេចក្តីណែនាំ
## ស្តីពី
## ការអនុវត្តនីតិវិធីសម្រាប់ការចំណាយថវិកាចរន្ត ក្នុងក្របខណ្ឌរដ្ឋបាលខណ្ឌ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)

ស្របតាមផែនការសកម្មភាពនៃការអនុវត្តគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជំហានទី៣ ឆ្នាំ ២០២១-២០២៥ និង ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា លេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោង FMIS បានចុះសិក្សា និង ប្រមូលធាតុចូលនៅរដ្ឋបាលខណ្ឌសម្រាប់ការរៀបចំ និង ដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាចរន្តតាម FMIS ទាំងស្រុងក្នុងឆ្នាំ ២០២៤ ដែលការអនុវត្តនេះឆ្លើយតបទៅនឹងស្ថានភាពនៃការអនុវត្តជាក់ស្តែងរបស់រដ្ឋបាលខណ្ឌ និង ការអនុវត្តការងារហិរញ្ញវត្ថុកាន់តែមានប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាព ។

អង្គភាពដែលត្រូវចូលរួមអនុវត្តនីតិវិធីថ្មីនេះ រួមមាន÷ រដ្ឋបាលខណ្ឌចំនួន **១៤** (ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ) មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី និង រតនាគាររាជធានី ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់អង្គភាពដែលត្រូវចូលរួមអនុវត្តនីតិវិធីថ្មីនេះ ដូចតទៅ÷

**១. នីតិវិធីថ្មីនេះអនុវត្តលើមុខសញ្ញាចំណាយថវិកាចរន្តដូចមានក្នុងតារាងខាងក្រោម÷**

| ល.រ | ជំពូក | បរិយាយ |
|---|---|---|
| ១ | ៦០ | ការទិញ |
| ២ | ៦១ | សេវាកម្ម |
| ៣ | ៦២ | អត្ថប្រយោជន៍សង្គម |
| ៤ | ៦៣ | ពន្ធ និង អាករ |
| ៥ | ៦៤ | បន្ទុកបុគ្គលិក |
| ៦ | ៦៥ | ឧបត្ថម្ភធន |

**២. នីតិវិធីថ្មីនេះត្រូវអនុវត្តផ្អែកតាមនីតិវិធីអនុវត្តស្តង់ដា ខាងក្រោម÷**

**២.១. នីតិវិធីស្នើសុំធានាចំណាយ**

- SOPCK001- នីតិវិធីធានាចំណាយកិច្ចលទ្ធកម្មរបស់រដ្ឋបាលខណ្ឌ
- SOPCK002- នីតិវិធីធានាចំណាយមិនមានគោលរបបកំណត់របស់រដ្ឋបាលខណ្ឌ
- SOPCK003- នីតិវិធីធានាចំណាយបុរេប្រទានរបស់រដ្ឋបាលខណ្ឌ

**២.២. នីតិវិធីអនុវត្តកិច្ចលទ្ធកម្ម**

- SOPPK001- នីតិវិធីការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលខណ្ឌ

**២.៣. នីតិវិធីទូទាត់ចំណាយ**

- SOPPKS01- នីតិវិធីទូទាត់កិច្ចលទ្ធកម្ម
- SOPPKS02- នីតិវិធីអាណត្តិចំណាយមានគោលរបបកំណត់
- SOPPKS03- នីតិវិធីអាណត្តិចំណាយមិនមានគោលរបបកំណត់
- SOPPKS04- នីតិវិធីទូទាត់ជម្រះបុរេប្រទាន
- SOPPKS05- នីតិវិធីជម្រះរជ្ជទេយ្យបុរេប្រទាន
- SOPPKS06- នីតិវិធីទូទាត់ចំណាយតាមការបើកផ្តល់សាច់ប្រាក់មុន

*ដូចមានភ្ជាប់ជូនក្នុងឯកសារនីតិវិធីស្តង់ដារអនាគតថ្មី តាមរយៈ FMIS ទាំងស្រុង ។*

**៣.អង្គភាពដែលត្រូវចូលរួមអនុវត្តនីតិវិធីថ្មីនេះ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវ និង ខ្ជាប់ខ្ជួន ទៅតាមតួនាទី និង ភារកិច្ចរៀងខ្លួន ដូចមានរៀបរាប់ខាងក្រោម÷**

**៣.១.អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ និង រដ្ឋបាលខណ្ឌ** ត្រូវអនុវត្តដូចខាងក្រោម÷

***ករណីទី ១÷ មុខសញ្ញាធានាចំណាយ (លើកលែងធានាចំណាយបុរេប្រទាន) និង ទូទាត់ចំណាយថវិកាចរន្ត***

-មន្ត្រីទទួលបន្ទុកចុះប្រតិបត្តិការ (ដូចមានកំណត់ក្នុងចំណុច ២.១ និង ចំណុច ២.៣ ខាងលើ) ត្រូវប្រមូលឯកសារពាក់ព័ន្ធនឹងមុខសញ្ញាស្នើសុំចំណាយពីអង្គភាពពាក់ព័ន្ធរបស់ខ្លួន រួចធ្វើការបង្កើតប្រតិបត្តិការធានាចំណាយ ឬ ចំណាយថវិកានៅក្នុង FMIS ដោយបំពេញបន្ថែមព័ត៌មានចាំបាច់នានានៅក្នុងប្រតិបត្តិការផ្ទាល់ឱ្យបានត្រឹមត្រូវ ច្បាស់លាស់ និង ស្កេនភ្ជាប់មកជាមួយនូវឯកសារ ឬ លិខិតយុត្តិការសម្រាប់ធានាចំណាយ ឬ ទូទាត់ចំណាយថវិកាចរន្ត (ដូចមានលម្អិតក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ) ដើម្បីជាមូលដ្ឋានក្នុងការត្រួតពិនិត្យ និង អនុម័ត ឬ ការធ្វើអធិការកិច្ចហិរញ្ញវត្ថុ ឬ ការធ្វើសវនកម្ម រួចបញ្ជូនទៅអ្នកត្រួតពិនិត្យ និង អ្នកអនុម័តក្នុងនាមជាអាណាប័កដើមខ្សែតាម FMIS ដោយមិនតម្រូវឱ្យមានការរៀបចំ និង បញ្ជូនឯកសារខាងក្រៅ FMIS ឡើយ ។ ឯកសារ ឬ លិខិតយុត្តិការសម្រាប់ធានាចំណាយ ឬ ទូទាត់ចំណាយថវិកាចរន្តច្បាប់ដើមត្រូវរក្សាទុកនៅអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ដើម្បីជាកម្មវត្ថុនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុ ឬ សវនកម្ម

**-មន្ត្រី និង/ឬ ថ្នាក់ដឹកនាំទទួលបន្ទុកត្រួតពិនិត្យ និង ទទួលបន្ទុកអនុម័តក្នុងនាមជាអាណាប័កដើមខ្សែ** ត្រូវត្រួតពិនិត្យជាបន្តបន្ទាប់គ្នា និង អនុម័តលើប្រតិបត្តិការធានាចំណាយ (លើកលែងធានាចំណាយបុរេប្រទាន) និង ចំណាយថវិកាចរន្តខាងលើនៅក្នុង FMIS ជាផ្លូវការ ដោយពុំមានឯកសារជាក្រដាសនៅខាងក្រៅ FMIS សម្រាប់ត្រួតពិនិត្យ និង អនុម័តទៀតទេ រួចបញ្ជូនបន្តទៅមន្ត្រី និង/ឬ ថ្នាក់ដឹកនាំ ត្រួតពិនិត្យហិរញ្ញវត្ថុក្នុងនាមជាអភិបាលហិរញ្ញវត្ថុ តាមរំហូរនៅក្នុង FMIS ។

***ករណីទី ២÷ មុខសញ្ញាធានាចំណាយបុរេប្រទាន***

-មន្ត្រីទទួលបន្ទុកចុះប្រតិបត្តិការបុរេប្រទាន (ដូចមានកំណត់ក្នុងចំណុច ២.១ ខាងលើ) ត្រូវរៀបចំឯកសារយុត្តិការជាក្រដាសផ្សេងៗទៅតាមនីតិវិធីបច្ចុប្បន្នរួច ត្រូវបង្កើតប្រតិបត្តិការធានាចំណាយបុរេប្រទាន ដោយបំពេញបន្ថែមព័ត៌មានចាំបាច់នានានៅក្នុងប្រតិបត្តិការផ្ទាល់ឱ្យបានត្រឹមត្រូវ ច្បាស់លាស់ក្នុង FMIS រួចបញ្ជូនទាំង ឯកសារយុត្តិការជាក្រដាសផ្សេងៗ និង ប្រតិបត្តិការធានាចំណាយបុរេប្រទានតាម FMIS ទៅអ្នកត្រួតពិនិត្យ និង អ្នកអនុម័តក្នុងនាមជាអាណាប័កដើមខ្សែ ដើម្បីត្រួតពិនិត្យ និង អនុម័ត

**-មន្ត្រី និង/ឬ ថ្នាក់ដឹកនាំទទួលបន្ទុកត្រួតពិនិត្យ និង ទទួលបន្ទុកអនុម័តក្នុងនាមជាអាណាប័កដើមខ្សែ** ត្រូវត្រួតពិនិត្យជាបន្តបន្ទាប់គ្នា និង អនុម័តលើប្រតិបត្តិការធានាចំណាយបុរេប្រទានខាងលើនៅក្នុង FMIS ជាផ្លូវការ ព្រមគ្នាជាមួយឯកសារយុត្តិការចំណាយជាក្រដាសនៅខាងក្រៅតាមនីតិវិធីបច្ចុប្បន្ន រួចបញ្ជូនបន្តទាំងប្រតិបត្តិការតាមវិហ្វូរនៅក្នុងFMIS និង ឯកសារយុត្តិការចំណាយជាក្រដាសទៅ មន្ត្រី និង/ឬ ថ្នាក់ដឹកនាំ ត្រួតពិនិត្យហិរញ្ញវត្ថុក្នុងនាមជាអភិបាលហិរញ្ញវត្ថុ ។

*<u>ករណីទី ៣÷ មុខសញ្ញាអនុវត្តកិច្ចលទ្ធកម្មសាធារណៈ</u>*

-មន្ត្រីទទួលបន្ទុកចុះប្រតិបត្តិការលទ្ធកម្ម (ដូចមានកំណត់ក្នុងចំណុច ២.២ ខាងលើ) ត្រូវរៀបចំឯកសារយុត្តិការសម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈជាក្រដាសផ្សេងៗទៅតាមនីតិវិធីបច្ចុប្បន្ន រួចត្រូវបង្កើតប្រតិបត្តិការអនុវត្តកិច្ចលទ្ធកម្ម (PO-P2P) ដោយបំពេញបន្ថែមព័ត៌មានចាំបាច់នានានៅក្នុងប្រតិបត្តិការឱ្យបានត្រឹមត្រូវ ច្បាស់លាស់ក្នុង FMIS រួចបញ្ជូនទាំងឯកសារយុត្តិការសម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈជាក្រដាសផ្សេងៗ និង ប្រតិបត្តិការ តាម FMIS ទៅអ្នកត្រួតពិនិត្យ និង អ្នកអនុម័តក្នុងនាមជាអាណាប័កដើមខ្សែ ដើម្បីត្រួតពិនិត្យ និង អនុម័ត

**-មន្ត្រី ឬ ថ្នាក់ដឹកនាំទទួលបន្ទុកអនុម័តក្នុងនាមជាអាណាប័កដើមខ្សែ** ត្រូវត្រួតពិនិត្យ និង អនុម័តផ្ដាច់លើប្រតិបត្តិការអនុវត្តកិច្ចលទ្ធកម្ម (PO-P2P) ខាងលើនៅក្នុង FMIS ជាផ្លូវការ ព្រមគ្នាជាមួយឯកសារយុត្តិការជាក្រដាសនៅខាងក្រៅតាមនីតិវិធីបច្ចុប្បន្នសម្រាប់ការអនុវត្តក្រោមសិទ្ធិសម្រេច ។ ដោយឡែក សម្រាប់ប្រតិបត្តិការអនុវត្តកិច្ចលទ្ធកម្ម (PO-P2P) លើសសិទ្ធិសម្រេច ក្រោយពី **មន្ត្រី ឬ ថ្នាក់ដឹកនាំទទួលបន្ទុកអនុម័តក្នុងនាមជាអាណាប័កដើមខ្សែ** បានចុះហត្ថលេខាសម្រេចលើឯកសារយុត្តិការ និង បានអនុម័តប្រតិបត្តិការ (PO-P2P) ខាងលើនៅក្នុង FMIS រួចរាល់ ត្រូវបន្តបញ្ជូនឯកសារយុត្តិការជាក្រដាស និង ប្រតិបត្តិការតាមវិហ្វូរនៅក្នុង FMIS ទៅ **មន្ត្រី និង/ឬ ថ្នាក់ដឹកនាំ ក្នុងនាមជាអភិបាលហិរញ្ញវត្ថុ ដើម្បីត្រួតពិនិត្យ និង អនុម័ត** ។

**៣.២.មន្ត្រី និង/ឬ ថ្នាក់ដឹកនាំ នៃមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានីភ្នំពេញ ក្នុងនាមជាអភិបាលហិរញ្ញវត្ថុ** ត្រូវអនុវត្តដូចខាងក្រោម÷

*<u>ករណីទី ១÷ មុខសញ្ញាធានាចំណាយ (លើកលែងបុរេប្រទាន) និង អាណត្តិទូទាត់</u>*

**- មន្ត្រី និង/ឬ ថ្នាក់ដឹកនាំទទួលបន្ទុកត្រួតពិនិត្យ និង អនុម័ត** ត្រូវធ្វើការត្រួតពិនិត្យជាបន្តបន្ទាប់ និង អនុម័តសម្រេចចុងក្រោយ (ដូចមានកំណត់ក្នុងចំណុច ២.១ និង ចំណុច ២.៣. ខាងលើ) ក្នុងនាមជាអភិបាលហិរញ្ញវត្ថុនៅក្នុង FMIS ជាផ្លូវការបន្ទាប់ពីទទួលបាននូវប្រតិបត្តិការធានាចំណាយ និង ប្រតិបត្តិការចំណាយថវិកាចរន្ត ដែលបញ្ជូនពីរដ្ឋបាលខណ្ឌតាមវិហ្វូរនីតិវិធីអនុវត្តការងារក្នុង FMIS ដោយពុំមានឯកសារជាក្រដាសនៅខាងក្រៅ FMIS ទៀតទេ រួចបញ្ជូនបន្តតាម FMIS ទៅរតនាគាររាជធានី ។

*<u>ករណីទី ២÷ មុខសញ្ញាធានាចំណាយបុរេប្រទាន</u>*

**- មន្ត្រី និង/ឬ ថ្នាក់ដឹកនាំទទួលបន្ទុកត្រួតពិនិត្យ និង អនុម័ត** ត្រូវធ្វើការត្រួតពិនិត្យជាបន្តបន្ទាប់ និង អនុម័តសម្រេចចុងក្រោយលើប្រតិបត្តិការ (ដូចមានកំណត់ក្នុងចំណុច ២.១) ក្នុងនាមជាអភិបាលហិរញ្ញវត្ថុ រួមទាំងប្រតិបត្តិការធានាចំណាយនៅក្នុង FMIS និង ឯកសារយុត្តិការចំណាយដែលបញ្ជូនពីរដ្ឋបាលខណ្ឌ រួចបញ្ជូនបន្តទៅរតនាគាររាជធានីសម្រាប់បើកសាច់ប្រាក់បុរេប្រទាន ។

*<u>ករណីទី ៣÷ មុខសញ្ញាកិច្ចលទ្ធកម្មលើសសិទ្ធិសម្រេច</u>*

**- មន្ត្រី និង/ឬ ថ្នាក់ដឹកនាំទទួលបន្ទុកត្រួតពិនិត្យ និង អនុម័ត** ត្រូវធ្វើការត្រួតពិនិត្យជាបន្តបន្ទាប់ និង អនុម័តសម្រេចចុងក្រោយលើប្រតិបត្តិការកិច្ចលទ្ធកម្ម (ដូចមានកំណត់ក្នុងចំណុច២.២) ក្នុងនាមជាអភិបាលហិរញ្ញវត្ថុ នៅក្នុង FMIS និង ឯកសារយុត្តិការនានាដែលបញ្ជូនពីរដ្ឋបាលខណ្ឌ ។

**៣.៣.មន្ត្រី និង/ឬ ថ្នាក់ដឹកនាំ នៃរតនាគាររាជធានី ក្នុងនាមជាគណនេយ្យករសាធារណៈ** ត្រូវត្រួតពិនិត្យ និង ទូទាត់ដូចតទៅ÷

**ក.នៅដំណាក់កាលប្រតិបត្តិការចំណាយថវិកាចរន្ត**

- បន្ទាប់ពីទទួលបានប្រតិបត្តិការទូទាត់ចំណាយខាងលើតាមវិហ្វរក្នុង FMIS ពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **មន្ត្រី និង/ឬ ថ្នាក់ដឹកនាំ ទទួលបន្ទុកត្រួតពិនិត្យ** ត្រូវត្រួតពិនិត្យ កាត់ពន្ធ និង អនុម័តប្រតិបត្តិការចំណាយខាងលើ ដោយពិនិត្យតាមដានព័ត៌មាន និង ទិន្នន័យពាក់ព័ន្ធនៅក្នុង FMIS ព្រមទាំងពិនិត្យលិខិតយុត្តិការចំណាយដែលបានស្កែនចូលក្នុង FMIS តាមនីតិវិធីជាធរមាន រួចបញ្ជូនបន្តទៅអ្នកទទួលបន្ទុកអនុម័តប្រតិបត្តិការចំណាយតាម FMIS ដោយពុំរង់ចាំការត្រួតពិនិត្យឯកសារខាងក្រៅទៀតនោះទេ

-**មន្ត្រី និង/ឬ ថ្នាក់ដឹកនាំ ទទួលបន្ទុកអនុម័ត** ត្រូវបន្តពិនិត្យ និង អនុម័តលើប្រតិបត្តិការចំណាយខាងលើនៅក្នុង FMIS ជាផ្លូវការតែម្តង និង បន្តបញ្ចប់ប្រតិបត្តិការចំណាយថវិកាតាមនីតិវិធីនៅក្នុង FMIS រួចបញ្ជូនបន្តទៅកាន់មន្ត្រីទទួលបន្ទុកទូទាត់ចំណាយ ។

**ខ.នៅដំណាក់កាលប្រតិបត្តិការទូទាត់សាច់ប្រាក់**

ក្រោយទទួលបានប្រតិបត្តិការចំណាយទូទាត់ខាងលើ និង ឯកសារគតិយុត្តពាក់ព័ន្ធ ដែលបានស្កែនភ្ជាប់មកជាមួយក្នុង FMIS មន្ត្រីទទួលបន្ទុកទូទាត់សាច់ប្រាក់ត្រូវរៀបចំទូទាត់ជូនអ្នកទទួលផល តាមការស្នើសុំរបស់រដ្ឋបាលខណ្ឌ ។

ចំពោះដំណើរការប្រតិបត្តិការចំណាយទូទាត់ខាងលើ ក្នុងករណីពិនិត្យឃើញថាពុំទាន់ត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន និង មិនអនុលោមតាមបទប្បញ្ញត្តិផ្សេងៗនៃសេចក្តីណែនាំនេះ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី និង រតនាគាររាជធានី ទទួលបន្ទុកមានសិទ្ធិស្នើសុំការបំភ្លឺ និង សាកសួរបន្ថែម, មិនធ្វើការអនុម័ត ឬ មិនទូទាត់ជូនអ្នកទទួលផលរបស់រដ្ឋបាលខណ្ឌ ។ ក្នុងករណីរុញត្រលប់, បដិសេធប្រតិបត្តិការ ឬ មិនទូទាត់ជូននោះ ត្រូវបញ្ជូនប្រតិបត្តិការចំណាយខាងលើត្រលប់ទៅកាន់រដ្ឋបាលខណ្ឌវិញតាម FMIS ដោយមានបញ្ជាក់ពីចំណុចខ្វះខាត ។ ក្រោយពីធ្វើការកែតម្រូវ ឬ ស្កែនបន្ថែមលិខិតយុត្តិការដែលនៅខ្វះ រដ្ឋបាលខណ្ឌត្រូវបញ្ជូនប្រតិបត្តិការឡើងវិញតាម FMIS ស្របតាមនីតិវិធីកំណត់ខាងលើ ។

រដ្ឋបាលខណ្ឌ ដូចមានបញ្ជាក់ក្នុងសេចក្តីណែនាំនេះ និង គ្រប់អង្គភាពពាក់ព័ន្ធនៃមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី និង រតនាគាររាជធានីត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០២៤ នេះតទៅ ។

ថ្ងៃចន្ទ ១១ រោច ខែបុស្ស ឆ្នាំ ថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ នៃក្រសួងមហាផ្ទៃ
-អគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-អគ្គនាយកដ្ឋានរតនាគារជាតិ
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
-អគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-គ្រប់រដ្ឋបាលរាជធានី-ខេត្ត
"ដើម្បីជូនជ្រាប"
-រតនាគាររាជធានីភ្នំពេញ
-មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានីភ្នំពេញ
-រដ្ឋបាលខណ្ឌ ក្នុងឧបសម្ព័ន្ធភ្ជាប់
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

*តារាងឧបសម្ព័ន្ធភ្ជាប់តាមសេចក្តីណែនាំលេខ..០០៥..សហវ.សណ.គអ.ជគជ... ចុះថ្ងៃទី..៥...ខែ..កុម្ភៈ..ឆ្នាំ..២០២៤ ស្តីពីការអនុវត្តនីតិវិធីសម្រាប់ការចំណាយថវិកាចរន្តក្នុងក្របខណ្ឌរដ្ឋបាលខណ្ឌ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)*

## តារាងសម្រង់លិខិតយុត្តិការសម្រាប់នីតិវិធីចំណាយថវិកាចរន្តដែលត្រូវស្កេនបញ្ចូលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ក្នុងក្របខណ្ឌរដ្ឋបាលខណ្ឌ

លិខិតយុត្តិការចំណាយដែលត្រូវស្កេនបញ្ចូលក្នុង FMIS សម្រាប់មុខសញ្ញាចំណាយថវិកាចរន្តក្នុងក្របខណ្ឌរដ្ឋបាលខណ្ឌ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ត្រូវបានកំណត់តាមប្រភេទមុខសញ្ញាចំណាយនីមួយៗ តាមលំដាប់លេខ ដូចមានលម្អិតក្នុងតារាងខាងក្រោម៖

| ល.រ | មុខសញ្ញាចំណាយ | លិខិតយុត្តិការចំណាយ |
|---|---|---|
| I | **នីតិវិធីធានាចំណាយ** | |
| ១ | ធានាចំណាយកិច្ចលទ្ធកម្ម | **ក. ស្កេនចូលប្រព័ន្ធ**<br>១. លិខិតស្នើសុំអង្គភាពផ្ទៃក្នុងរបស់រដ្ឋបាលខណ្ឌ<br>២. តារាងគម្រោងចំណាយលម្អិតតាមមាតិកាថវិកា និង តាមមុខទំនិញ<br>៣. គំនូរប្លង់សម្រាប់កិច្ចលទ្ធកម្មសំណង់<br>៤. ផែនការលទ្ធកម្ម/ផែនការលទ្ធកម្មកែតម្រូវ<br>៥. គំរូកាតាឡុកទំនិញ<br>៦. រូបភាពសំណង់ដែលត្រូវជួសជុល<br>៧. វិក្កយបត្រស្ទង់តម្លៃ<br>**ខ. រក្សាទុកនៅសាមីអង្គភាព**<br>(មិនមាន) |
| ២ | ធានាចំណាយមិនមានគោលរបបកំណត់ | **ក. ស្កេនចូលប្រព័ន្ធ**<br>១. លិខិតស្នើសុំអង្គភាពផ្ទៃក្នុងរបស់រដ្ឋបាលខណ្ឌ<br>២. តារាងគម្រោងចំណាយលម្អិតតាមមាតិកាថវិកា តាមចំណាត់ថ្នាក់សេដ្ឋកិច្ច និង ចំណាត់ថ្នាក់កម្មវិធី<br>៣. វិក្កយបត្រចំណាយ ទឹក អគ្គិសនី ទូរសព្ទ របស់ក្រុមហ៊ុនឯកជន<br>៤. ប័ណ្ណប៉ាតង់ត្រូវតាមប្រភេទទំនិញ ឬ សេវាដូចមានចែងនៅក្នុងកិច្ចសន្យា<br>៥. គោលការណ៍អនុញ្ញាតពី កសហវ សម្រាប់បេសកកម្មលើសគោលរបប ១០ថ្ងៃ ក្នុង និង ក្រៅប្រទេស និង របាយការណ៍លទ្ធផល<br>**ខ. រក្សាទុកនៅសាមីអង្គភាព**<br>(មិនមាន) |
| II | **នីតិវិធីទូទាត់ចំណាយ** | |

| ល.រ | មុខសញ្ញាចំណាយ | លិខិតយុត្តិការចំណាយ |
|---|---|---|
| ៣ | ទូទាត់ចំណាយកិច្ចលទ្ធកម្ម | **ក. ស្ពែនចូលប្រព័ន្ធ**<br>១. លិខិតអញ្ជើញបើកឯកសារដេញថ្លៃ<br>២. ការផ្សព្វផ្សាយសេចក្ដីជូនដំណឹងស្ដីពីការដេញថ្លៃ/ពិគ្រោះថ្លៃ/ស្ទង់តម្លៃ (តាមរយៈសារព័ត៌មាន, គេហទំព័រ និង កាលបរិច្ឆេទ)<br>៣. កំណត់ហេតុបើកសំណើស្ទង់តម្លៃ/ចរចាថ្លៃ/ពិគ្រោះថ្លៃ<br>៤. កំណត់ហេតុវាយតម្លៃស្ដីពីការប្រគល់ទទួលកិច្ចសន្យា<br>៥. លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា (១០%)<br>៦. កិច្ចសន្យាលទ្ធកម្មដែលមានពន្ធប្រថាប់ត្រាដោយអង្គភាពពន្ធដារ រួមទាំងតារាងឧបសម្ព័ន្ធភ្ជាប់កិច្ចសន្យា<br>៧. កំណត់ហេតុវាយតម្លៃលទ្ធផលការងារ ឬ កំណត់ហេតុប្រគល់-ទទួល<br>៨. បញ្ជីវត្តមានចូលរួមវាយតម្លៃលទ្ធផលការងារ ឬ ប្រគល់-ទទួល<br>៩. ប័ណ្ណបញ្ចេញបញ្ចូលឃ្លាំង (ក្នុងករណីការផ្គត់ផ្គង់ទំនិញ)<br>១០. ប័ណ្ណប៉ាតង់ (ដែលមានសកម្មភាពអាជីវកម្មស្របតាមការផ្គត់ផ្គង់ ត្រូវតាមប្រភេទទំនិញ ឬ សេវាដូចមានចែងនៅក្នុងកិច្ចសន្យា)<br>១១. គោលការណ៍ ឬ លិខិតស្នើសុំករណីដាច់ដោយឡែក<br>១២. លិខិតបញ្ជាក់លេខគណនី ឈ្មោះ ធនាគារ និង ឈ្មោះម្ចាស់គណនី<br>១៣. លិខិតសម្រេចជ្រើសរើស និង ប្រគល់កិច្ចសន្យា<br>១៤. វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម អ.ត.ប (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)<br>**ខ. រក្សាទុកនៅសាមីអង្គភាព**<br>១. បញ្ជីវត្តមានចូលរួមវាយតម្លៃ និង ការប្រគល់ទទួលកិច្ចសន្យា<br>២. សំណើសុំប្រគល់ទទួល (ក្រុមហ៊ុន) |
| ៤ | ទូទាត់ចំណាយដែលមានគោលរបបកំណត់ | **ក. ស្កែនចូលប្រព័ន្ធ**<br>១. លិខិតស្នើសុំទូទាត់អង្គភាពផ្ទៃក្នុងរបស់រដ្ឋបាលខណ្ឌ<br>២. វិក្កយបត្រ / សក្ខីបត្រចំណាយ<br>៣. តារាងចំណាយជាក់ស្ដែងលម្អិតតាមមាតិកាថវិកា<br>៤. តារាងស្ដីពីថវិកាឧបត្ថម្ភធនតាមត្រីមាស (តារាងស្ដីពីថវិកាឧបត្ថម្ភធនតាមត្រីមាស)<br>៥. លិខិតជូនដំណឹងរបស់អង្គការអន្តរជាតិស្ដីពីថវិកាប្រចាំឆ្នាំដែលត្រូវបង់ (បង់វិភាគទានដល់អង្គការអន្តរជាតិនានា)<br>៦. អត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារជាតិ (បង់វិភាគទានដល់អង្គការអន្តរជាតិនានា)<br>៧. លិខិតអញ្ជើញពីម្ចាស់ប្រទេស<br>៨. ទិដ្ឋាការចេញ ចូល ឬ Boarding Pass<br>៩. របាយការណ៍ចំណាយជាក់ស្ដែង<br>១០. លិខិតអនុញ្ញាតជាគោលការណ៍<br>១១. របាយការណ៍ចំណាយជាក់ស្ដែង (បេសកកម្មក្នុងប្រទេស)<br>១២. លិខិតបញ្ជាបេសកកម្ម និង ទិដ្ឋាការធ្វើដំណើរ (បេសកកម្មក្នុងប្រទេស) |

| ល.រ | មុខសញ្ញាចំណាយ | លិខិតយុត្តិការចំណាយ |
|---|---|---|
| | | ១៣. លិខិតបញ្ជាបេសកកម្មក្រៅប្រទេស<br>**ខ. រក្សាទុកនៅសាមីអង្គភាព**<br>(មិនមាន) |
| ៥ | ទូទាត់ចំណាយមិនមានគោលរបបកំណត់ | **ក. ស្កែនចូលប្រព័ន្ធ**<br>១. លិខិតស្នើសុំទូទាត់អង្គភាពផ្ទៃក្នុងរបស់រដ្ឋបាលខណ្ឌ<br>២. វិក្កយបត្រ / សក្ខីបត្រចំណាយតាមមុខសញ្ញាចំណាយ និង នីតិវិធីពាក់ព័ន្ធ<br>៣. លិខិតបញ្ជាក់លេខគណនី ឈ្មោះ ធនាគារ និង ឈ្មោះម្ចាស់គណនី<br>៤. របាយការណ៍សម្រង់ចំណាយទូទាត់ត្រង់មិនមានគោលរបបកំណត់ (មានហត្ថលេខា ទទួលស្គាល់ដោយប្រធានអង្គភាពថវិកា)<br>៥. តារាងបូកសរុបថាមពលអគ្គិសនី ទឹកស្អាត សេវាទូរសព្ទ ទូរសារ និង ប្រៃសណីយ៍ (ទូទាត់អគ្គិសនី ទឹកស្អាត សេវាទូរសព្ទ ទូរសារ)<br>៦. វិក្កយបត្រជាក់ស្តែងដែលផ្តល់ឱ្យដោយអង្គភាពឯកជន និង មានការទទួលស្គាល់ពីក្រសួង-ស្ថាប័ន និង អង្គភាពសាធារណៈប្រហាក់ប្រហែល (ទូទាត់អគ្គិសនី ទឹកស្អាត សេវាទូរសព្ទ ទូរសារ)<br>៧. កិច្ចសន្យាជួល និង បង្កាន់ដៃបង់ពន្ធ<br>**ខ. រក្សាទុកនៅសាមីអង្គភាព**<br>(មិនមាន) |
| ៦ | ទូទាត់ជម្រះបុរេប្រទាន | **ក. ស្កែនចូលប្រព័ន្ធ**<br>១. លិខិតស្នើសុំទូទាត់បុរេប្រទាន ផ្ទៃក្នុងរបស់រដ្ឋបាលខណ្ឌ<br>២. លិខិតសម្រេចផ្តល់បុរេប្រទាន<br>៣. វិក្កយបត្រ/ សក្ខីបត្រចំណាយទៅតាមមុខសញ្ញាចំណាយ និង នីតិវិធីពាក់ព័ន្ធ<br>៤. របាយការណ៍ចំណាយថវិកាបុរេប្រទាន<br>៥. លិខិតបង្វែរទឹកប្រាក់ដែលនៅសល់ពីចំណាយជាក់ស្តែងចូលរតនាគាររាជធានី<br>**ខ. រក្សាទុកនៅសាមីអង្គភាព**<br>(មិនមាន) |
| ៧ | ទូទាត់ជម្រះរដ្ឋទេយ្យបុរេប្រទាន | **ក. ស្កែនចូលប្រព័ន្ធ**<br>១. លិខិតស្នើសុំទូទាត់អង្គភាពផ្ទៃក្នុងរបស់រដ្ឋបាលខណ្ឌ<br>២. គម្រោងចំណាយ<br>៣. វិក្កយបត្រ ឬ សក្ខីបត្រចំណាយ<br>៤. ប័ណ្ណចំណាយ<br>៥. របាយការណ៍ចំណាយរដ្ឋទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និង ចំណាត់ថ្នាក់កម្មវិធីដែលមានលេខប័ណ្ណចំណាយ, កាលបរិច្ឆេទ និង បរិយាយកម្មវត្ថុចំណាយច្បាស់លាស់<br>៦. ប័ណ្ណដកប្រាក់រដ្ឋទេយ្យបុរេប្រទាន<br>៧. តារាងរបាយការណ៍ចំណាយរដ្ឋទេយ្យបុរេប្រទាន |

| ល.រ | មុខសញ្ញាចំណាយ | លិខិតយុត្តិការចំណាយ |
|---|---|---|
| | | ៨. ផែនការរដ្ឋទេយ្យបុរេប្រទានប្រចាំឆ្នាំ ឬ ផែនការកែសម្រួល<br>៩. តារាងតាមដានស្ថានភាពរដ្ឋទេយ្យបុរេប្រទានតាមប័ណ្ណដកសាច់ប្រាក់ និង អាណត្តិទូទាត់<br>**ខ. រក្សាទុកនៅសាមីអង្គភាព**<br>(មិនមាន) |
| ៨ | នីតិវិធីទូទាត់ចំណាយតាមការបើកផ្តល់សាច់ប្រាក់មុន | **ក. ស្នែនចូលប្រព័ន្ធ**<br>១. ផែនការបើកផ្តល់សាច់ប្រាក់មុន (សម្រាប់បេសកកម្មនៅក្នុងប្រទេស, សិក្ខាសាលា ឬ វគ្គបណ្តុះបណ្តាល និង កិច្ចប្រជុំផ្សេងៗ)<br>២. លិខិតបញ្ជាបេសកកម្ម<br>៣. ទិដ្ឋាការធ្វើដំណើរ<br>៤. តារាងទូទាត់ចំណាយប្រាក់បេសកកម្មនៅក្នុងប្រទេស<br>៥. ប័ណ្ណដកប្រាក់បេសកកម្មបើកផ្តល់មុន ឬ លិខិតស្នើសុំបំពេញបេឡា<br>៦. វិក្កយបត្រ<br>៧. ប័ណ្ណចំណាយ<br>៨. សក្ខីបត្រចំណាយ<br>៩. របាយការណ៍ចំណាយរៀបចំសិក្ខាសាលា ឬ វគ្គបណ្តុះបណ្តាល និង កិច្ចប្រជុំផ្សេងៗ<br>១០. តារាងតាមដានស្ថានភាពសាច់ប្រាក់បើកផ្តល់មុនតាមប័ណ្ណដកសាច់ប្រាក់<br>១១. របាយការណ៍លទ្ធផលការងារនៃការចុះបេសកកម្ម<br>**ខ. រក្សាទុកនៅសាមីអង្គភាព**<br>សំណើស្នើសុំប្រាក់បេសកកម្ម |

*តារាងឧបសម្ព័ន្ធភ្ជាប់តាមសេចក្តីណែនាំលេខ ០០៥ សហវ........ ចុះថ្ងៃទី...៥...ខែ...កុម្ភៈ...ឆ្នាំ...២០២៤......*
*ស្តីពីការអនុវត្តនីតិវិធីសម្រាប់ការចំណាយថវិកាថវិកាថវិកាចរន្តក្នុងក្របខណ្ឌរដ្ឋបាលខណ្ឌ*
*តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)*

**តារាងបញ្ជីរាយនាមរដ្ឋបាលខណ្ឌ ដែលត្រូវចូលរួមអនុវត្តនីតិវិធីសម្រាប់ការចំណាយថវិកាចរន្ត**
**តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)**

រដ្ឋបាលខណ្ឌចំនួន ១៤ ដូចមានលម្អិតក្នុងតារាងខាងក្រោមត្រូវចូលរួមអនុវត្តនីតិវិធីសម្រាប់ការចំណាយថវិកាចរន្ត ក្នុងក្របខណ្ឌរដ្ឋបាលខណ្ឌ រួមមាន÷

| ល.រ | រដ្ឋបាលខណ្ឌ |
|---|---|
| ១ | ខណ្ឌចំការមន |
| ២ | ខណ្ឌដូនពេញ |
| ៣ | ខណ្ឌ៧មករា |
| ៤ | ខណ្ឌទួលគោក |
| ៥ | ខណ្ឌដង្កោ |
| ៦ | ខណ្ឌមានជ័យ |
| ៧ | ខណ្ឌឫស្សីកែវ |
| ៨ | ខណ្ឌសែនសុខ |
| ៩ | ខណ្ឌពោធិ៍សែនជ័យ |
| ១០ | ខណ្ឌជ្រោយចង្វារ |
| ១១ | ខណ្ឌព្រែកព្នៅ |
| ១២ | ខណ្ឌច្បារអំពៅ |
| ១៣ | ខណ្ឌបឹងកេងកង |
| ១៤ | ខណ្ឌកំបូល |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៧៩០ ឧវបន.តក.ប្រក

ថ្ងៃ.........ខែ........ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...... ខែ....... ឆ្នាំ២០២៣

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ០៧៧/១១ ស.ត.ស.ព ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតសក់សិប្បនិម្មិត របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣ របស់ក្រុមហ៊ុន រីប៊ីកា ហែរ ប្រដាក់ (ខេមបូឌា)

## សម្រេច

**ប្រការ១:** អនុញ្ញាតឱ្យក្រុមហ៊ុន **រីប៊ីកា ហែរ ប្រដាក់ (ខេមបូឌា) (REBECCA HAIR PRODUCTS (CAMBODIA) CO., LTD.)** តំណាងដោយលោកស្រី **ZHENG, WENQING** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **EF5458651** ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ បង្កើតរោងចក្រ**ផលិតសក់សិប្បនិម្មិត** ដែលមានទីតាំងស្ថិតនៅ**តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (ភូមិពូធឿង ឃុំបិតត្រាំង និងភូមិស្ទឹងជ្រៅ ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ)**។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សក់សិប្បនិម្មិត | ៣២៩០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ **"រោងចក្រផលិតសក់សិប្បនិម្មិត វិបីកា ហ៊ែរ ប្រដាក់ (ខេមបូឌា)"**

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ០១៧ ឧស.កឧ.ប្រក.០១ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងលិខិតលេខ៥៦៩០ ឧវបន.កឧ.លស ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការប្តូរអភិបាល របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-ខុទ្ទកាល័យរដ្ឋមន្ត្រី
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តព្រះសីហនុ
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តព្រះសីហនុ
-អង្គភាពរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ
-រដ្ឋបាលស្រុកព្រៃនប់
-រដ្ឋបាលឃុំបិតត្រាំង និងឃុំរាម
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
រដ្ឋលេខាធិការ

ហោង សុខគង់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: [illegible]

ថ្ងៃ សុក្រ ៧ រោច ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៨ ខែ កញ្ញា ឆ្នាំ២០២៣

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងវិញ្ញាបនបត្រចុះបញ្ជីគម្រោងវិនិយោគលេខ៤៣៦/២៣ ក.អ.ក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ ស្តីពីការបង្កើតរោងចក្រផលិតកាបូបគ្រប់ប្រភេទ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងលិខិតលេខ២៩៤០/២៣ គ.វ.ក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការប្តូរអភិបាល និងប្តូរនាមករណ៍របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ របស់ក្រុមហ៊ុន រីចប៊ែក (ខេមបូឌា) ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន រីចប៊ែក (ខេមបូឌា) ឯ.ក **(RICHBAGS (CAMBODIA) CO., LTD.)** គ្រប់គ្រងដោយលោក **XIONG, MINGCAI** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ**EF1818665** ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ បង្កើតរោងចក្រផលិតកាបូបគ្រប់ប្រភេទ ដែលមានទីតាំងស្ថិតនៅភូមិស្លែង ឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| កាបូបគ្រប់ប្រភេទ | ១៥១២ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " រោងចក្រផលិតកាបូបគ្រប់ប្រភេទ រីចប៊ែក (ខេមបូឌា) ឯ.ក "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបាន ឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការ របស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា ១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

